ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

របាយការណ៍

បូកសរុបលទ្ធផលការងាររយៈពេល ០១ឆ្នាំ ខែកញ្ញា ឆ្នាំ២០១៣ ដល់ខែសីហា ឆ្នាំ២០១៤ និងទិសដៅបន្ត ឆ្នាំ២០១៤-២០១៥ របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

I-លទ្ធផលនៃការអនុវត្តកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលអាណាត្តិទី៥ លើវិស័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ២០១៣-២០១៤

ក្នុងរយៈពេល០១ឆ្នាំនេះ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (ស.អ.យ) ខិតខំអនុវត្តគោលនយោបាយប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់នូវកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលអាណាត្តិទី៥ ជាពិសេស ជំរុញអនុវត្តគោលនយោបាយសមធម៌សង្គម លើកតម្កើងជីវភាពរស់នៅរបស់ប្រជាជនក្នុងសង្គមបង្កើនការឧបត្ថម្ភ គាំទ្រ ទាំងសម្ភារៈ និងស្មារតី បង្កលក្ខណៈផ្តល់សេវាសង្គមកិច្ចដោយបង្កើតឲ្យមានគោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត កម្មវិធីនានា និងយន្តការ ដើម្បីផ្តល់សេវាសង្គមកិច្ច ជួយដល់ក្រុមជនរងគ្រោះ និងងាយរងគ្រោះ ជាអាទិ៍ ជនក្រីក្រ រងគ្រោះដោយគ្រោះធម្មជាតិ គ្រោះមហន្តរាយជាយថាហេតុផ្សេងៗ ជនក្រីក្រងាយរងគ្រោះនៅតាមសហគមន៍ ជនចាស់ជរាគ្មានទីពឹង ជនអនាថា ជនពិការ កុមារនៃគ្រួសារក្រីក្រ កុមារកំព្រា កុមាររងផលប៉ះពាល់ដោយអំពើហិង្សា កុមារប្រព្រឹត្តល្មើសនឹងច្បាប់ កុមារអនាថា ជនរងគ្រោះដោយសារធាតុញៀន ជនរងគ្រោះដោយជំងឺកាចសាហាវផ្សេងៗ និងដោយអំពើជួញដូរមនុស្សគ្រប់រូបភាព។ល។ ខិតខំទប់ស្កាត់ទុរគតភាព និងភាពងាយរងគ្រោះក្នុងសង្គម ការរំលោភបំពាន លើកស្ទួយសិទ្ធិជាមូលដ្ឋានរបស់ប្រជាពលរដ្ឋ ដើម្បីបង្កើតឡើងនូវស្ថានភាពរីកចម្រើនព្រមៗគ្នាក្នុងសហគមន៍។

រៀបចំ និងអនុវត្តគោលនយោបាយ របបសន្តិសុខសង្គម និងកម្មវិធីនានាដើម្បីលើកកម្ពស់តួនាទី និងសុខុមាលភាពរបស់អតីតមន្ត្រីរាជការស៊ីវិល និងអតីតយុទ្ធជន។

អនុវត្តកម្មវិធីនយោបាយដ៏ត្រឹមត្រូវរបស់រាជរដ្ឋាភិបាលកម្ពុជាដែលមាន **"យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣"** របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាធ្វើជាស្នូល។ ត្រង់មុំទី៣ "ការអភិវឌ្ឍប្រព័ន្ធគាំពារសង្គម" និងមុំទី៤ "ការជំរុញអនុវត្តគោលនយោបាយជាតិប្រជាជន និងសមភាពយេនឌ័រ" នៃចតុកោណទី៤ បានញ្ជាំងឲ្យក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានដាក់ចេញនូវយុទ្ធសាស្ត្រ ០៣ យ៉ាងគឺ៖ ទី១. បង្កើនប្រសិទ្ធភាពសេវាសុខុមាលភាពសង្គម ទី២. ពង្រឹងពង្រីកប្រព័ន្ធសន្តិសុខសង្គម និងទី៣. ពង្រឹងសមត្ថភាពស្ថាប័ន និងកៀរគរប្រភពធនធានទាំងផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុ។

ក្រសួងបានដឹកនាំវិស័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សម្រេចបានសមិទ្ធផលជាក់ស្តែងលើកម្មវិធីការងារអាទិភាពចំនួន ០៨ មានដូចតទៅ៖

១-អភិវឌ្ឍសុខុមាលភាពជនរងគ្រោះ និងជាយរងគ្រោះ និងកិច្ចការគ្រួសារ

-បានបង្កើត និងអនុវត្តកម្មវិធីសង្គ្រោះបន្ទាន់ ដើម្បីជួយដល់ប្រជាជនរងគ្រោះដោយគ្រោះធម្មជាតិ គ្រោះមហន្តរាយជាយថាហេតុផ្សេងៗ ដោយមិនទុកឲ្យប្រជាជនណាម្នាក់រងគ្រោះដោយមិនបានជួយយកចិត្តទុក

ដាក់ពីស្ថាប័នមានសមត្ថកិច្ចឡើយ។ តាមរយៈកម្មវិធីនេះ បានជួយប្រជាជនក្រីក្រ ទុរគតជន ប្រជាជនរងគ្រោះដោយគ្រោះធម្មជាតិ រងគ្រោះដោយគ្រោះមហន្តរាយផ្សេងៗ។ល។ ចំនួន ៤៧.២៧៥គ្រួសារ ក្នុងនោះ មានខេត្តកំពង់ឆ្នាំង ៣១៥៤គ្រួសារ ព្រៃវែង ៨៦០គ្រួសារ កំពង់ស្ពឺ ៣០៣គ្រួសារ កណ្តាល ១៧៤២គ្រួសារ ស្វាយរៀង ៩២គ្រួសារ កំពង់ចាម ២១១០គ្រួសារ កំពង់ធំ ០៧គ្រួសារ ក្រចេះ ០៧គ្រួសារ ស្ទឹងត្រែង ១០៧៩ គ្រួសារ កំពត ១៦២៥គ្រួសារ កែប ៨០គ្រួសារ បាត់ដំបង ៣៥៥០៦គ្រួសារ បន្ទាយមានជ័យ ៥៩៣គ្រួសារ ឧត្តរមានជ័យ ៩៩គ្រួសារ និងខេត្តប៉ៃលិន ១៨គ្រួសារ ត្រូវបានទប់ស្កាត់ និងកាត់បន្ថយការធ្វើចំណាកស្រុក ដោយបង្កលក្ខណសម្បត្តិសម្រាប់ការស្តារជីវភាពឡើងវិញ និងក ធ្វើសមាហរណកម្មទៅក្នុងសហគមន៍

-បានរៀបចំគោលនយោបាយ និងយន្តការសម្រាប់ជួយជនអនាថានៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីជួយដោះស្រាយបញ្ហាជនអនាថាប្រកបដោយមនុស្សធម៌ និងការគោរពសិទ្ធិជាមូលដ្ឋានរបស់ជនរងគ្រោះ។ ជនអនាថាចំនួន ៧២៩គ្រួសារ ក្នុងនោះ មានរាជធានីភ្នំពេញ ៣៣៤នាក់ ខេត្តកំពង់ធំ ៦៨នាក់ ឧត្តរមានជ័យ ១៩នាក់ ស្ទឹងត្រែង ០៩នាក់ បន្ទាយមានជ័យ ១៧៤នាក់ កំពង់ឆ្នាំង ៣៦នាក់ តាកែវ ២៩នាក់ កំពត ១៤នាក់ កំពង់ចាម ០៩នាក់ ស្វាយរៀង ៣៥នាក់ និងខេត្តកោះកុង ០២នាក់ ត្រូវបានសង្គ្រោះ ផ្តល់សេវាស្តារនីតិសម្បទា ការថែទាំសុខភាព អប់រំផ្លូវចិត្ត បណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងសមាហរណកម្មទៅសហគមន៍ ចំនួន ៣៦៤នាក់ និងបានផ្សព្វផ្សាយឲ្យយល់ដឹងពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាពបានចំនួន ៥០.៨៥១នាក់

-បានផ្តល់សេវាថែទាំ និងគាំទ្រនៅសហគមន៍ដល់ជនរងគ្រោះ និងរងផលប៉ះពាល់ដោយសារមេរោគអេដស៍ ជំងឺអេដស៍ និងជំងឺកាចសាហាវផ្សេងៗបានចំនួន ៥.៤១៧នាក់ ក្នុងនោះមាន ខេត្តសៀមរាប ១៦៩៨ នាក់ កែប ២៧នាក់ ស្វាយរៀង ១០៦នាក់ កំពង់ស្ពឺ ៨៣៩នាក់ កណ្តាល ៤៥នាក់ កំពត ១៤នាក់ កំពង់ចាម ១៥០នាក់ បន្ទាយមានជ័យ ១២៩នាក់ កំពង់ឆ្នាំង ១៩៦៨នាក់ និងខេត្តកំពង់ធំ ៤៤១នាក់

-បានបង្កើត និងអនុវត្តកម្មវិធីស្តីពីការអភិវឌ្ឍគ្រួសារ បំផុសលើកទឹកចិត្តការកសាងគ្រួសារល្អ ទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ រៀបចំទិវាជាតិ និងអន្តរជាតិស្តីពីគ្រួសារ ១៥ ឧសភា ឆ្នាំ២០១៤ ក្រោមប្រធានបទ "**អភិវឌ្ឍគ្រួសារជាគ្រឹះនៃការអភិវឌ្ឍជាតិ**"។ គ្រួសារជាច្រើន បានរក្សាប្រពៃណីទំនៀមទម្លាប់ល្អរស់នៅប្រកបដោយសុភមង្គលក្នុងសង្គមដែលមានសុខសន្តិភាព និងអភិវឌ្ឍន៍។ ទន្ទឹមនេះ រាជធានីភ្នំពេញ ខេត្តកណ្តាល កំពត ព្រៃវែង កែប ព្រះសីហនុ និងខេត្តបាត់ដំបងក៏បានប្រារព្ធទិវានេះផងដែរ។ បានផ្សព្វផ្សាយទស្សនាទានយេនឌ័រ និងអនុសញ្ញា ស៊ី-ដ ដល់មន្ត្រីបង្គោលទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិបានចំនួន ១៣៥នាក់ ទន្ទឹម នាពេលថ្មីនេះ ក្រសួង និងមន្ទីរ ស.អ.យ បានសហការជាមួយស្ថាប័នពាក់ព័ន្ធចូលរួមទទួលពលករចំណាកស្រុកដែលបញ្ជូនយ៉ាងគំហុកពីប្រទេសថៃប្រមាណ ២០៧.៤៩២នាក់ ស្រីចំនួន ៧៥.៤១២នាក់ កុមារចំនួន ២០.០៧៤នាក់

-បានរៀបចំគោលនយោបាយ បទដ្ឋានអប្បបរមា និងកម្មវិធីសម្រាប់ជួយដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស សំដៅប្រយុទ្ធប្រឆាំងឧក្រិដ្ឋកម្មជួញដូរមនុស្ស និងសង្គ្រោះជនរងគ្រោះ ជាអាទិ៍ ក្នុងឆ្នាំ២០១៤ នេះ បានរៀបចំវគ្គបណ្តុះបណ្តាលអំពីគោលនយោបាយ និងបទដ្ឋានអប្បបរមាដល់មន្ត្រី ស.អ.យ នៅខេត្តស្វាយរៀង សៀមរាប កំពង់ស្ពឺ និងខេត្តកោះកុង ចំនួន ១៤៤នាក់

-បានចេញប្រកាសលេខ ១២៧៤ សអយ ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៤ ស្តីពីបទដ្ឋានអប្បបរមាសម្រាប់ការថែទាំជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទស្នាក់នៅមណ្ឌល និងសេចក្តីព្រាងគោលការណ៍ណែនាំ ស្តីពីការកំណត់អត្តសញ្ញាណនិងការបញ្ជូលជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងអំពើអាជីវកម្មផ្លូវភេទ និងសេចក្តីព្រាងឧបករណ៍ត្រួតពិនិត្យនិងវាយតម្លៃការអនុវត្តគោលនយោបាយ និងបទដ្ឋានអប្បបរមាស្តីពីកិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស ព្រមទាំងបានបណ្តុះបណ្តាលអនុវត្តសាកល្បងចំនួន ០២លើក នៅខេត្តសៀមរាប

-បានចូលរួមកិច្ចប្រជុំ សិក្ខាសាលានៅក្រៅប្រទេស ក្នុងតំបន់ និងពិភពលោក ដើម្បីសិក្សា ស្រាវជ្រាវ ផ្លាស់ប្តូរបទពិសោធន៍ពាក់ព័ន្ធនឹងអំពើហិង្សាលើស្ត្រីនិងកុមារ អំពើជួញដូរមនុស្សនិងអាជីវកម្មផ្លូវភេទ

-បានធ្វើមាតុភូមិនិវត្តន៍ជនរងគ្រោះជាជនជាតិវៀតណាមចំនួន ២១ករណី

-បានសហការជាមួយអង្គការដៃគូដើម្បីជួយជនរងគ្រោះ ដោយអំពើជួញដូរមនុស្សចំនួន៣២៦ករណី ក្នុងនោះ បានធ្វើសមាហរណកម្មចំនួន ១៤៨ករណី ឆ្លើយតបករណីចំនួន ១៥ករណី បញ្ជូនទៅទទួលសេវាបន្តចំនួន ១៣៤ករណី បិទករណីចំនួន ០២ករណី និងតាមដានបន្តចំនួន ២៧ករណី។ ដោយឡែក មណ្ឌលសំចតប៉ោយប៉ែតបានទទួលជនរងគ្រោះដោយអំពើជួញដូរមនុស្សចំនួន ២០៣ករណី និងបានបញ្ជូនទៅទទួលសេវាបន្តនៅតាមអង្គការដៃគូនានា

-សហការជាមួយអង្គការ IOM ទទួលជនរងគ្រោះដោយអំពើជួញដូរមនុស្សចំនួន ១៤៦ករណី ក្នុងនោះ ឥណ្ឌូនេស៊ី ០៣ករណី ម៉ាឡេស៊ី ៣៣ករណី ថៃ ១០៤ករណី និងប្រទេសចិន ០៦ករណី ហើយជនរងគ្រោះទាំងនេះ បានធ្វើសមាហរណកម្មនៅរាជធានី ខេត្តចំនួន ១៦

-ខិតខំបន្តអនុវត្តកិច្ចព្រមព្រៀងទ្វេភាគី ពហុភាគីជាមួយប្រទេសជិតខាងក្នុងតំបន់ដើម្បីបង្កើនកិច្ចសហប្រតិបត្តិការក្នុងការទប់ស្កាត់អំពើជួញដូរមនុស្ស និងជួយជនរងគ្រោះ។ ជនរងគ្រោះដោយអំពើជួញដូរផ្លូវភេទ និងជួញដូរពលកម្ម រាប់រយនាក់ត្រូវបានសង្គ្រោះ ស្តារនីតិសម្បទា និងសមាហរណកម្ម

-កម្ពុជាបានទទួលការវាយតម្លៃនៅក្នុងកម្រិតទី២ (TIR 2) ជាកម្រិតល្អក្នុងពិភពលោកក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

២-អភិវឌ្ឍសុខុមាលភាពកុមារ និងយុវនីតិសម្បទា

ពាក់ព័ន្ធនឹងកិច្ចការពារកុមារ ជាពិសេស កុមាររងគ្រោះ និងងាយរងគ្រោះ ក្រសួងបានអនុវត្តយ៉ាងសកម្មនូវគោលនយោបាយថែទាំជំនួសចំពោះកុមារ និងបទដ្ឋានអប្បបរមា ស្តីពីការថែទាំជំនួសចំពោះកុមារ លិខិតបទដ្ឋាននានា ពាក់ព័ន្ធនឹងកុមារទាំងជាតិ និងអន្តរជាតិ សំដៅអភិវឌ្ឍវិស័យសុខុមាលភាពកុមារឲ្យបានល្អប្រសើរ ទាំងផ្នែកសុខភាព ផ្នែកអប់រំសិក្សាធិការ ផ្នែកទប់ស្កាត់រាល់អំពើកេងប្រវ័ញ្ចគ្រប់រូបភាពលើកុមារ និងបង្កឱកាសឲ្យកុមារចូលរួមធ្វើសេចក្តីសម្រេចរបស់ខ្លួនក្នុងផែនការអភិវឌ្ឍន៍នៅមូលដ្ឋាន ដោយឈរលើគោលការណ៍រក្សាសិទ្ធិទាំងបួនរបស់កុមារ និងខិតខំលើកកម្ពស់ការវិនិយោគវិស័យកុមារក្លាយជាមូលធនមនុស្សប្រកបដោយសក្តានុពល ដែលផ្តើមចេញពីការអភិវឌ្ឍគ្រួសារនីមួយៗ មានកូនល្អ សិស្សល្អ មិត្តល្អ និងជាពលរដ្ឋល្អរបស់សង្គមជាតិ

-បានរៀបចំរបាយការណ៍ ស្តីពីសិទ្ធិទទួលបានយុត្តិធម៌សម្រាប់កុមារ ដើម្បីឆ្លើយតបទៅនឹងសេចក្តីសម្រេចលេខ ២២/៣២ ដែលពាក់ព័ន្ធនឹងសិទ្ធិទទួលបានបទដ្ឋានសុខភាពខ្ពស់បំផុតរបស់កុមារ និងបានផ្ញើជូនក្រុមប្រឹក្សាសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ

-បានរៀបចំ និងចងក្រងសូចនាករ ស្តីពីសិទ្ធិកុមារ ដែលមានចំនួន ៦៦សូចនាករ និងកំពុងរៀបចំបញ្ចូលក្នុងប្រព័ន្ធ CamInfor របស់វិទ្យាស្ថានជាតិស្ថិតិរបស់ក្រសួងផែនការ

-បានរៀបចំ ចងក្រង និងបោះពុម្ពកម្រងច្បាប់ គោលនយោបាយ និងមុខងារពាក់ព័ន្ធនឹងការការពារកុមារ (Compendium Law) និងបានចែកជូនដល់ក្រសួង ស្ថាប័ន និងអង្គការមិនមែនរដ្ឋាភិបាលពាក់ព័ន្ធ

-បានរៀបចំ និងបោះពុម្ពសៀវភៅសិក្សា ស្តីពីសិទ្ធិកុមារ និងបានរៀបចំវគ្គបំប៉ន់ចំនួន ០១លើក ដល់ក្រុមកាងារដើម្បីកុមារមកពីក្រសួង ស្ថាប័ន មន្ត្រីលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ (ក.ជ.ក) ខេត្តតាកែវ និងតំណាងអង្គការមិនមែនរដ្ឋាភិបាលពាក់ព័ន្ធ

-បានរៀបចំ និងបោះពុម្ពសេចក្តីសម្រេចស្តីពីគោលការណ៍ណែនាំសម្រាប់អនុវត្តការចូលរួមរបស់កុមារ និងផ្សព្វផ្សាយទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ

-ក្រសួងនៅតែបន្តលើកកម្ពស់ ជំរុញការផ្សព្វផ្សាយ និងអនុវត្តយ៉ាងទូលំទូលាយនូវសិទ្ធិជាមូលដ្ឋានទាំងបួនរបស់កុមារដែលមានចែងក្នុងច្បាប់កំពូលរបស់ព្រះរាជាណាចក្រកម្ពុជា មាត្រា៣១ និងមាត្រា ៤៨ និងអនុសញ្ញានៃអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ រួមមាន សិទ្ធិរស់រានមានជីវិត សិទ្ធិទទួលបានការអភិវឌ្ឍ សិទ្ធិទទួលបានការការពារ និងសិទ្ធិចូលរួម តាមរយៈការប្រជុំជីវភាព កសាងគ្រួសារល្អ និងទិវាកុមារអន្តរជាតិ ០១ មិថុនា ខួបលើកទី១៣ ទិវាពិភពលោកប្រឆាំងពលកម្មកុមារ ១២មិថុនា និងទិវាកុមារកម្ពុជាឆ្នាំ២០១៤ ក្រោមប្រធានបទ "**រួមគ្នាលុបបំបាត់អំពើហិង្សាលើកុមារ និងពង្រីកកិច្ចគាំពារសង្គមដើម្បីប្រយុទ្ធប្រឆាំងពលកម្មកុមារ**" ដោយមានអ្នកចូលរួមចំនួន ២.៣៥០នាក់

-បានរៀបចំវគ្គបំប៉ន់មន្ត្រីជំនាញចំនួន ០៧លើក ស្តីពីច្បាប់ពាក់ព័ន្ធនឹងការការពារសិទ្ធិកុមាររងគ្រោះ ដោយសារការជួញដូរ នៅខេត្តចំនួន ០៧ រួមមាន ខេត្តកណ្តាល តាកែវ កំពត ស្វាយរៀង ព្រៃវែង កោះកុង និងខេត្តព្រះសីហនុ មានអ្នកចូលរួមចំនួន ១៨២នាក់

-ក្នុងគោលបំណងរៀបចំដំណើរការយន្តការជាតិ ពាក់ព័ន្ធកុមារ ដើម្បីពង្រឹងប្រសិទ្ធភាព និងប្រសិទ្ធផលការងារក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ រាជរដ្ឋាភិបាលបានចេញអនុក្រឹត្យលេខ ៣៨២ អនក្រ.តត ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៤ ស្តីពីការតែងតាំងសមាសភាពក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ

-បានរៀបចំវគ្គបណ្តុះបណ្តាលចំនួន ០៦លើក រួមមាន វគ្គបណ្តុះបណ្តាលស្តីពីការរៀបចំថវិកាតាមកម្មវិធី និងកំណែទម្រង់ប្រព័ន្ធថវិកា វគ្គបណ្តុះបណ្តាលស្តីពីការតាមដាននិងវាយតម្លៃ វគ្គបណ្តុះបណ្តាលស្តីពីការរៀបចំកម្មវិធីសិទ្ធិកុមារ វគ្គបណ្តុះបណ្តាលស្តីពីវិធីសាស្ត្រស្រាវជ្រាវសង្គម វគ្គបណ្តុះបណ្តាលស្តីពីការរៀបចំផែនការថវិកាផ្សារភ្ជាប់នឹងគោលនយោបាយជាតិសម្រាប់កុមារ និងវគ្គបណ្តុះបណ្តាលភាសាអង់គ្លេសដល់មន្ត្រីក្រសួង ស.អ.យ មន្ត្រីអគ្គលេខាធិការដ្ឋាន ក.ជ.ក និងមន្ត្រីលេខាធិការដ្ឋាន ក.ជ.ក រាជធានី ខេត្ត

-បានរៀបចំកិច្ចប្រជុំផ្សព្វផ្សាយសេចក្តីប្រកាសស្តីពីការលុបបំបាត់អំពើហិង្សាលើស្ត្រី និងការលុបបំបាត់អំពើហិង្សាលើកុមារនៅក្នុងអាស៊ាន ដែលមានអ្នកចូលរួមចំនួន ៦៥នាក់

-បានអនុវត្តកាតព្វកិច្ចជាសមាជិកនៃការអនុវត្តអនុសញ្ញាសិទ្ធិកុមារ បានរៀបចំ និងផ្ញើរបាយការណ៍ជាតិលើកទី២ និងលើកទី៣ ស្តីពីការអនុវត្តអនុសញ្ញាសិទ្ធិកុមារ និងរបាយការណ៍ជាតិស្តីពីការអនុវត្តពិធីសារពាក់ព័ន្ធផ្សេងទៀតជូនអង្គការសហប្រជាជាតិ បានទាន់ពេលវេលាប្រកបដោយគុណភាព។ បានពង្រឹងពង្រីកយន្តការតាមដាន និងអនុវត្តសិទ្ធិកុមារ តាមក្រសួង ស្ថាប័ន និងរាជធានី ខេត្ត និងបានចេញសារាចរណែនាំស្តីពីការអនុវត្តអនុសាសន៍របស់អង្គការសហប្រជាជាតិស្តីពីការអនុវត្តអនុសញ្ញា ស្តីពីសិទ្ធិកុមារ

-បានរួមចំណែកយ៉ាងសកម្មជាមួយស្ថាប័នពាក់ព័ន្ធ អាជ្ញាធរជាតិ និងថ្នាក់ក្រោមជាតិ ក្នុងការអនុវត្តប្រកបដោយជោគជ័យ នូវគោលដៅជាច្រើននៃគោលដៅអភិវឌ្ឍន៍សហវត្សដែលពាក់ព័ន្ធនឹងវិស័យកុមារ ជាអាទ៍ លើវិស័យសុខាភិបាល និងវិស័យអប់រំ រួមមាន: ការកាត់បន្ថយអត្រាមរណភាពមាតា និងទារក អប់រំ ការបង្កើនអត្រាចូលរៀនរបស់សិស្ស និងគុណភាពអប់រំ។ល។

-បានបំពេញតួនាទីយ៉ាងសកម្ម ជាសេនាធិការរបស់ក្រសួង ក្នុងការលើកកម្ពស់ប្រព័ន្ធសុខុមាលភាពកុមារ តាមរយៈ ធ្វើបច្ចុប្បន្នភាព កសាងលិខិតបទដ្ឋាននានាពាក់ព័ន្ធនឹងកុមារ ជាពិសេស កុមារងាយរងគ្រោះ ដូចជា ប្រកាសស្តីពីនីតិវិធីអនុវត្តគោលនយោបាយថែទាំជំនួសចំពោះកុមារ ប្រកាសស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អាជ្ញាធរកណ្តាលស្ទុំកូនអន្តរប្រទេស រដ្ឋបាលស្ទុំកូនអន្តរប្រទេស ប្រកាសស្តីពីនីតិវិធីអនុវត្តច្បាប់ស្ទុំកូនអន្តរប្រទេស សេចក្តីព្រាងអនុក្រឹត្យ ស្តីពីការគ្រប់គ្រងមណ្ឌលថែទាំកុមារ សេចក្តីព្រាងអនុក្រឹត្យ ស្តីពីរបបគោលនយោបាយចំពោះជនរងគ្រោះដែលស្នាក់នៅក្នុងមណ្ឌលរបស់រដ្ឋ សេចក្តីព្រាងក្រមសីលធម៌ ស្តីពីកិច្ចគាំពារកុមារ សេចក្តីព្រាងគោលការណ៍ណែនាំ ស្តីពីការតាមដាន និងវាយតម្លៃកុមារកំព្រា និងកុមារងាយរងគ្រោះ ប្រកាសស្តីពីការបញ្ចេញបញ្ចូលជនរងគ្រោះដោយសារការប្រើប្រាស់គ្រឿងញៀន សេចក្តីព្រាង

អនុក្រឹត្យ ស្តីពីវិធីសាស្ត្រព្យាបាល និងគ្រប់គ្រងវិធានការព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន សេចក្តីព្រាងប្រកាសអន្តរក្រសួងស្តីពីការបន្សាប ព្យាបាលទាំងផ្លូវកាយ និងផ្លូវចិត្តអ្នកញៀនគ្រឿងញៀន។ល។

-បានបន្តសហការជាមួយដៃគូពាក់ព័ន្ធ អង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិ សង្គមស៊ីវិល ជាពិសេស ជាមួយអង្គការយូនីសេហ្វ បានជំរុញការអនុវត្តប្រកបដោយផ្លែផ្កានូវប្រព័ន្ធសុខុមាលភាពកុមារ។ ទន្ទឹមនេះ បានផ្តល់ការបណ្តុះបណ្តាលពង្រឹងសមត្ថភាពមន្ត្រីលើនីតិវិធីអនុវត្តគោលនយោបាយ ស្តីពីការថែទាំជំនួសចំពោះកុមារ នីតិវិធី ស្តីពីការគ្រប់គ្រងករណី ការងារស្មុំកូន និងការបង្រួបបង្រួមកុមារចេញពីមណ្ឌលទៅគ្រួសារ និងសហគមន៍វិញ ដល់មន្ត្រីពាក់ព័ន្ធនៅថ្នាក់រាជធានី ខេត្ត (ខេត្តបាត់ដំបង បន្ទាយមានជ័យ ស្វាយរៀង សៀមរាប ព្រៃវែង ព្រះសីហនុ កំពង់ស្ពឺ ខេត្តកណ្តាល និងរាជធានីភ្នំពេញ) សរុបអ្នកចូលរួមចំនួន ១.៩៣៧ នាក់ ព្រមទាំងបានចេញសេចក្តីសម្រេចស្តីពីការបង្កើតគណៈកម្មាធិការគ្រប់គ្រងករណី និងការបង្រួបបង្រួមកុមារចេញពីមណ្ឌលទៅគ្រួសារ និងសហគមន៍នៅខេត្តសៀមរាប និងឈានទៅបង្កើតខេត្តដទៃទៀត។ ទន្ទឹមនឹងនេះ ក្រុមការងារថ្នាក់ជាតិពហុវិស័យស្តីពីកុមារកំព្រា និងកុមារងាយរងគ្រោះ បានបន្តធ្វើការផ្សព្វផ្សាយបទដ្ឋាន និងគោលការណ៍ណែនាំ ការគាំទ្រ និងការគាំពារចំពោះកុមារកំព្រា និងកុមារងាយរងគ្រោះ ដល់មន្ត្រីរបស់មន្ទីរ អង្គការពាក់ព័ន្ធ អង្គការសង្គមស៊ីវិល និងគណៈកម្មាធិការទទួលបន្ទុកកិច្ចការស្ត្រី និងកុមារ ថ្នាក់ខេត្ត ថ្នាក់ស្រុក និងគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារយុំ សង្កាត់ នៅខេត្ត ក្រុងចំនួន ១៤ សំដៅលើកកម្ពស់ការយល់ដឹង ចូលរួមកំណត់អត្តសញ្ញាណកុមារកំព្រា និងកុមារងាយរងគ្រោះ និងតម្រូវការសេវាចាំបាច់ ដើម្បីដាក់បញ្ចូលក្នុងកម្មវិធីវិនិយោគ និងផែនការអភិវឌ្ឍន៍យុំ សង្កាត់ ស្របតាមគោលនយោបាយគណៈកម្មាធិការជាតិគាំទ្រយុំ សង្កាត់ ផ្នែកសកម្មភាពយុំសង្កាត់នៅក្នុងកិច្ចការពារកុមារ និងពង្រឹងការកសាងផែនការប្រតិបត្តិប្រចាំឆ្នាំ ដោយប្រើប្រាស់កញ្ចប់ថវិការបស់យុំ សង្កាត់ ស្របតាមសេចក្តីណែនាំ ស្តីពីការអនុវត្តមុខងាររបស់គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារយុំ សង្កាត់ ក្នុងការអនុវត្តផ្នែកសង្គមពាក់ព័ន្ធនឹងសុខភាពមាតា មត្តេយ្យសិក្សាលេខ ០៥១ ក.ណ.ន/ត.ជ.អ.ប ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១០ របស់ក្រសួងមហាផ្ទៃ។ ក្រៅពីនេះ បានសហការជាមួយអង្គការមិនមែនរដ្ឋាភិបាលជាសមាជិកក្រុមការងារថ្នាក់ជាតិពហុវិស័យ ស្តីពីកុមារកំព្រា និងកុមារងាយរងគ្រោះ (ក.ជ.ក.រ) និងអាជ្ញាធរខេត្តក្រុង ជាពិសេស ខេត្តបន្ទាយមានជ័យរួមគ្នាកៀរគរថវិកាទិញសម្ភារៈ ដើម្បីឧបត្ថម្ភជូនគ្រួសារពលករចំណាកស្រុកដែលត្រឡប់ពីប្រទេសថៃវិញ ដោយយកចិត្តទុកដាក់ចំពោះស្ត្រីមានផ្ទៃពោះ និងគ្រួសារមានកូនច្រើន បង្កលក្ខណៈងាយស្រួលក្នុងការធ្វើដំណើរឲ្យទៅដល់លំនៅឋានរបស់ពួកគេវិញ

-បានបន្តលើកកម្ពស់ និងពង្រឹងគុណភាពនៃការថែទាំកុមារនៅតាមមណ្ឌលរដ្ឋ និងអង្គការមិនមែនរដ្ឋាភិបាល តាមរយៈការធ្វើអធិការកិច្ច ការកាត់បន្ថយចំនួនមណ្ឌលដែលអនុវត្តមិនស្របតាមគោលនយោបាយ ស្តីពីការថែទាំជំនួសចំពោះកុមារ ជាក់ស្តែង ចាប់ពីខែកញ្ញា ឆ្នាំ២០១៣ ដល់ខែសីហា ឆ្នាំ២០១៤ ក្រសួងបានរកឃើញមណ្ឌលដែលអនុវត្តមិនសមស្របតាមគោលនយោបាយ ស្តីពីការថែទាំជំនួសចំពោះកុមារ ដោយបានបិទមណ្ឌលកម្មវិធីចិញ្ចឹមកុមារចំនួន ០១មណ្ឌល របស់អង្គការសមាគមក្តីសង្ឃឹមពលរដ្ឋខ្មែរ (CHHA) ដែលចុះកិច្ចព្រមព្រៀងជាមួយក្រសួង ស.អ.យ និងមណ្ឌលចំនួន ០៨ ដែលមិនបានចុះកិច្ចព្រមព្រៀងជាមួយក្រសួង ស.អ.យ រួមមាន - Love In Action – Hope transaction- សុខាសាកុមារកម្ពុជា- ផ្ទះរបស់ក្មេងនៃកម្ពុជា - អភិវឌ្ឍន៍កុមារសហគមន៍ - ផ្ទះកុមារនៅសៀមរាបរបស់លោក វេ ហាឡុង - Asia Home (2 Centers) - ម្លប់ឆ័ត្រ និងបានបង្វែរកុមារទាំងអស់ចំនួន ១៥៦នាក់ ទៅរស់នៅក្នុងមណ្ឌលរដ្ឋ អង្គការម្លប់ឬស្សី អាស្តេកា អង្គការភាពញញឹមនៃកុមារ (PSE)។ ព្រមជាមួយគ្នានេះ បានជំរុញការបង្រួបបង្រួមគ្រួសារកុមារតាមគោលការណ៍ផ្តល់អាទិភាពឲ្យកុមារទទួលបានការអភិវឌ្ឍក្នុងក្របខ័ណ្ឌគ្រួសារ។ ទន្ទឹមនោះ ខិតខំស្វែងរកគ្រួសារធម៌ ឬគ្រួសារចិញ្ចឹមក្នុងប្រទេសឲ្យអស់លទ្ធភាពមុននឹងឈានទៅដល់ដំណើរការស្មុំកូនអន្តរប្រទេស។ ក្នុងស្មារតីនេះ កុមារត្រូវតែមានផ្ទះនៅ កុមាររស់នៅជាមួយម្តាយ កុមារត្រូវតែមានបងប្អូន និងកុមារត្រូវតែរស់នៅក្នុងសហគមន៍

ដូចកុមារដទៃទៀតដែរ។ បានជំរុញការធ្វើបច្ចុប្បន្នភាពកុមារ និងកុមារជំទង់រស់នៅក្នុងមណ្ឌលរដ្ឋ និងអង្គការមិនមែនរដ្ឋាភិបាល សំដៅកាត់បន្ថយការរស់នៅក្នុងមណ្ឌល ដោយលើកទឹកចិត្តឲ្យទៅរស់នៅជាមួយឪពុកម្តាយ សាច់ញាតិនៅតាមសហគមន៍វិញ។ បានបណ្តុះបណ្តាលមន្ត្រីរដ្ឋបាលស្ទុះកូនអន្តរប្រទេសក្នុងប្រទេសចំនួន ០៥លើក និងក្រៅប្រទេសចំនួន ០៣លើក ដូចជា ការប្រជុំរៀនសូត្រ ដកពិសោធន៍ ការធ្វើសិក្ខាសាលាជាបន្តបន្ទាប់ និងបានបញ្ជូនមន្ត្រីទៅធ្វើទស្សនកិច្ច សិក្សានៅក្រៅប្រទេស។ ក្រៅពីនេះ នៅបានលើកទឹកចិត្តដល់ជនបរទេសដែលមកស្នាក់នៅ និងមានបេសកកម្មបំពេញការងាររយៈពេលយូរនៅក្នុងព្រះរាជាណាចក្រកម្ពុជា ក្នុងបុព្វហេតុមនុស្សធម៌ និងមានមនោសញ្ចេតនាស្រឡាញ់កុមារកំព្រា កុមារត្រូវបានបោះបង់ចោល ឬកុមារគ្មានទីពឹង អនុញ្ញាតឲ្យសុំយកកុមារទាំងនោះ ធ្វើជាកូនធម៌រស់នៅជាមួយស្របតាមគោលការណ៍ និងបទប្បញ្ញត្តិជាធរមានរបស់រាជរដ្ឋាភិបាល។ ទន្ទឹមនឹងការងារខាងលើ បានបង្កើនកិច្ចសហការយ៉ាងល្អជាមួយភាគីដៃគូ ស្ថាប័នរាជរដ្ឋាភិបាល ជាពិសេស ក្រសួងមហាផ្ទៃ ក្រសួងយុត្តិធម៌ ក្រសួងអប់រំ យុវជន និងកីឬា ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ។ល។ និងអង្គការមិនមែនរដ្ឋាភិបាល សង្គមស៊ីវិល និងដៃគូជាតិ អន្តរជាតិ ក្នុងកិច្ចការពារជួយកុមាររងគ្រោះ ទប់ស្កាត់អំពើហិង្សា ការរំលោភបំពានលើគ្រប់រូបភាព ជាពិសេសការរំលោភផ្លូវភេទ និងបានធ្វើការផ្តន្ទាទោសជនល្មើសទាំងជនជាតិខ្មែរ និងបរទេសជាបន្តបន្ទាប់

-បានជំរុញការអនុវត្តការងារយុវនីតិសម្បទា ដោយបង្កើត និងអនុវត្តនូវកម្មវិធីយុត្តិធម៌សម្រាប់អនីតិជន ផ្តល់នូវសេវាការពារសិទ្ធិកុមារតាមផ្លូវច្បាប់ និងទប់ស្កាត់អំពើល្មើសច្បាប់ដែលប្រព្រឹត្តដោយអនីតិជន និងយុវជននៅតាមសហគមន៍ និងបានបន្តពិភាក្សា តាមរយៈសិក្ខាសាលាជាច្រើនលើក ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ជាពិសេស ក្រសួងយុត្តិធម៌ ក្រសួងមហាផ្ទៃ និងអង្គការដៃគូរពាក់ព័ន្ធដើម្បីបញ្ចប់សេចក្តីព្រាងច្បាប់ស្តីពីយុត្តិធម៌អនីតិជន ដើម្បីការពារសិទ្ធិ និងឧត្តមប្រយោជន៍កុមារនៅក្នុងប្រព័ន្ធយុត្តិធម៌ និងទប់ស្កាត់បាតុភាពអសកម្មរបស់អនីតិជន ឲ្យបានរួចរាល់ និងឈានយកសេចក្តីព្រាងច្បាប់នេះទៅដាក់ឆ្លងក្នុងកិច្ចប្រជុំអន្តរក្រសួង

-បានរៀបចំគោលនយោបាយសម្រាប់អ្នកស្នាក់នៅមជ្ឈមណ្ឌលព្យាបាលស្តារនីតិសម្បទាសម្រាប់ជួយជនរងគ្រោះដែលប្រើប្រាស់បំពានសារធាតុញៀន ព្រមជាមួយនោះ បានជំរុញអនុវត្តគោលនយោបាយលើកទឹកចិត្តការព្យាបាល និងស្តារនីតិសម្បទាជនរងគ្រោះដែលប្រើប្រាស់បំពានសារធាតុញៀនតាមសហគមន៍ ដោយផ្អែកលើបទពិសោធន៍កម្មវិធីព្យាបាលនៅស្រុកម៉ាឡៃនៃខេត្តបន្ទាយមានជ័យ និងឈានទៅអនុវត្តការព្យាបាលនេះនៅរាជធានីភ្នំពេញ

-ត្រូវបានបង្កើតកិច្ចសហការជាមួយអង្គការពាក់ព័ន្ធជាដៃគូ និងក្រុមគ្រួសារជនរងគ្រោះដោយសារការប្រើប្រាស់គ្រឿងញៀន ដើម្បីកែលម្អ និងពង្រឹងគុណភាពមណ្ឌលរដ្ឋទាំង ០៧ និងរបស់អង្គការទាំង ០៤ សំដៅលើកកម្ពស់កម្មវិធីព្យាបាល ស្តារនីតិសម្បទា និងសមាហរណកម្មទៅសហគមន៍វិញឲ្យបានល្អប្រសើរ។ ទន្ទឹមនេះ បានដំណើរការគ្រប់គ្រងមជ្ឈមណ្ឌលជាតិព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀននៅភូមិគោករការ សង្កាត់ក្រាំងធ្នង់ ខណ្ឌសែនសុខ រាជធានីភ្នំពេញ ដើម្បីឈានទៅទទួលព្យាបាលជនរងគ្រោះដោយសារការប្រើប្រាស់គ្រឿងញៀន

-បានសហការជាមួយអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ក្រសួងសុខាភិបាល និងដៃគូរអភិវឌ្ឍន៍ពាក់ព័ន្ធ រៀបចំសេចក្តីព្រាងអនុក្រឹត្យ ស្តីពីនីតិវិធី និងវិធានការគ្រប់គ្រងស្តារនីតិសម្បទា និងសមាហរណកម្មអ្នកញៀនគ្រឿងញៀន និងប្រកាសអន្តរក្រសួង ស្តីពីការបន្សាប និងការព្យាបាលទាំងផ្លូវកាយ និងផ្លូវចិត្តអ្នកញៀនគ្រឿងញៀន។ បានបង្កើតគណៈកម្មាធិការត្រួតពិនិត្យ និងវាយតម្លៃមជ្ឈមណ្ឌលព្យាបាល បន្សាប និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនបណ្តោះអាសន្នរបស់រដ្ឋទាំង ០៧ ដើម្បីជ្រើសរើសមជ្ឈមណ្ឌលមួយធ្វើជាគំរូជាលក្ខណៈស្តង់ដា

-បានបញ្ជូនមន្ត្រីចំនួន ០៧នាក់ ទៅធ្វើការបណ្តុះបណ្តាល និងសិក្សាដកពិសោធន៍អំពីការស្តារនីតិសម្បទា អ្នកញៀនគ្រឿងញៀនជាមួយអង្គការដៃគូក្នុងប្រទេស និងក្រៅប្រទេស (វៀតណាម និងថៃ)។

៣-អភិវឌ្ឍសុខុមាលភាពជនពិការ

-បានជំរុញអនុវត្តច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ ស្របតាមគោលនយោបាយជាតិស្តីពីជនពិការ។ តាមរយៈច្បាប់នេះ គោលនយោបាយការពារ លើកកម្ពស់សិទ្ធិជនពិការ និងលុបបំបាត់ការរើសអើងចំពោះជនពិការ ត្រូវបានអនុវត្តយ៉ាងទូលំទូលាយ និងប្រកបដោយផ្លែផ្កា ព្រមទាំងបានបង្កឱកាសឲ្យជនពិការបានចូលរួមគ្រប់សកម្មភាពរបស់សង្គម

-បានបន្តជំរុញអនុវត្តអនុសញ្ញាអង្គការសហប្រជាជាតិ ស្តីពីសិទ្ធិជនពិការ និងទសវត្សរ៍ជនពិការប្រចាំតំបន់អាស៊ី និងប៉ាស៊ីហ្វិកឆ្នាំ២០១៣-២០២២ យុទ្ធសាស្ត្រអ៊ីនឈាន់ “**ធ្វើឲ្យសិទ្ធិក្លាយជាការពិត**” បន្ថែមលើបទដ្ឋានជាតិដែលមានស្រាប់

-បានរៀបចំទិវាជនពិការកម្ពុជាលើកទី១៥ និងទិវាជនពិការអន្តរជាតិលើកទី៣១ ឆ្នាំ២០១៣ និងទិវាផ្សេងៗទៀត សម្រាប់ជនពិការ

-បានរៀបចំ និងដាក់ឲ្យប្រើប្រាស់ជាផ្លូវការផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព ២០១៤- ២០១៨

-បានដាក់ឲ្យប្រើប្រាស់ផែនការយុទ្ធសាស្ត្ររបស់មូលនិធិជនពិការ ២០១៤-២០១៨ សម្រាប់កំណត់នូវការអនុវត្ត ការបន្ត និរន្តរភាពការផ្តល់សេវាស្តារលទ្ធភាពពលកម្មកាយសម្បទាប្រកបដោយគុណភាព និងការកែប្រែស្ថាប័នឲ្យក្លាយជាគ្រឹះស្ថានសាធារណរដ្ឋបាលពេញលេញ

-មូលនិធិជនពិការបានផ្តល់សេវាស្តារលទ្ធភាពពលកម្មកាយសម្បទាជូនជនពិការចំនួន ២៣.៩៣៥នាក់ ក្នុងនោះ បានផ្តល់សេវាព្យាបាលដោយចលនាចំនួន ៣៩.១៥៩ដង និងផ្តល់គ្រឿងអវយវៈសិប្បនិម្មិត និងរណបដោយឥតគិតថ្លៃ ព្រមទាំងការផ្តល់ប្រាក់សោហ៊ុយធ្វើដំណើរ និងប្រាក់សម្រាប់អាហារ។ ទន្ទឹមនេះ ក្រោមកិច្ចសហប្រតិបត្តិការជាមួយអង្គការដៃគូ បានផ្តល់សេវាស្តារលទ្ធភាពពលកម្មវេជ្ជសាស្ត្រប្រមាណ ២៨.៩១៧នាក់

-បានជំរុញដាក់ឲ្យអនុវត្តការផ្តល់របបគោលនយោបាយចំពោះជនពិការក្រីក្រនៅតាមសហគមន៍

-បានសម្របសម្រួលការអនុវត្តកម្មវិធីស្តារលទ្ធភាពពលកម្មនៅសហគមន៍ជូនជនពិការ និងការបង្កើតក្រុមជួយខ្លួនឯងនៃជនពិការចំនួន ២៥ក្រុម។ គិតពីឆ្នាំ១៩៩២ រហូតដល់បច្ចុប្បន្ន ក្រុមជួយខ្លួនឯងនៃជនពិការមានចំនួន ១.៩៥០ក្រុម

-បានបណ្តុះបណ្តាលវិជ្ជាជីវៈជនពិការចំនួន ១៥៥នាក់ និងបានអភិវឌ្ឍមុខរបរខ្នាតតូចជូនជនពិការនៅតាមសហគមន៍

-បានជំរុញក្រសួង ស្ថាប័នរដ្ឋ ក្នុងការជ្រើសរើសជនពិការចូលរួមបម្រើការងារតាមអត្រាកំណត់ ២% បច្ចុប្បន្ន ជនពិការចំនួន ១.២៦% នៃមន្ត្រីរាជការសរុបទទួលបានការងារធ្វើតាមក្រសួង ស្ថាប័នរដ្ឋ និងបានជំរុញឲ្យវិស័យឯកជនជ្រើសរើសជនពិការចូលបម្រើការងារក្នុងអត្រាកំណត់ ១%

-បានពង្រឹង ពង្រីកកម្មវិធីផ្តល់សេវាជូនកុមារពិការភ្នែក កុមារគរថ្លង់ និងកុមារខ្សោយសតិបញ្ញា តាមរយៈការបង្កើតឲ្យមានមណ្ឌលផ្តល់នូវសេវាពិសេសជូនដល់ប្រភេទកុមារពិការនីមួយៗ និងធ្វើសមាហរណកម្មកុមារពិការទៅក្នុងសហគមន៍ដោយមិនមានការរើសអើង

-បានលើកទឹកចិត្តចលនាកីឡា សិល្ប:របស់ជនពិការ ការងារផ្សព្វផ្សាយព័ត៌មានជាភាសាសញ្ញា និងការអភិវឌ្ឍសេវាអក្សរស្ទាប និងភាសាសញ្ញា។ ថ្មីៗនេះកីឡាជនពិការបានចូលរួមប្រកួតកីឡាអាស៊ានប៉ារ៉ាហ្គេមលើកទី៧នៅប្រទេសភូមា ទទួលមេដាយសរុបចំនួន ៣២គ្រឿង ក្នុងនោះ មេដាយមាស ០៤ មេដាយប្រាក់ ១១ និងមេដាយសំរិទ្ធ ១៧

-បានសម្របសម្រួលបញ្ជូនជនពិការទៅចូលរួមវគ្គបណ្តុះបណ្តាល និងព្រឹត្តិការណ៍នានាជាលក្ខណៈជាតិ និងអន្តរជាតិ

-បានសហការជាមួយមជ្ឈមណ្ឌលអភិវឌ្ឍន៍ជនពិការប្រចាំតំបន់អាស៊ី និងប៉ាស៊ីហ្វិក អនុវត្តគម្រោងសាកល្បង ស្តីពីបរិស្ថានគ្មានពិការភាព តាមរយៈការរៀបចំកែសម្រួលហេដ្ឋារចនាសម្ព័ន្ធ និងទីកន្លែងសាធារណៈ នៅឃុំឈើទាល ស្រុកគៀនស្វាយ ខេត្តកណ្តាល ដើម្បីបង្កលក្ខណៈងាយប្រើប្រាស់សម្រាប់ជនពិការ។

៤-អភិវឌ្ឍសុខុមាលភាពមនុស្សចាស់

-ដើម្បីសម្តែងនូវការដឹងគុណចំពោះគុណូបការៈដ៏ថ្លៃថ្លារបស់មនុស្សចាស់ ដែលបានបន្សល់ទុកនូវសមិទ្ធផល និងមរតកជាច្រើននោះ រាជរដ្ឋាភិបាលបានកសាងលិខិតបទដ្ឋានគតិយុត្ត និងគោលនយោបាយជាតិជាបន្តបន្ទាប់ ចាប់តាំងពីក្រោយថ្ងៃរំដោះ ៧មករា ១៩៧៩មក សំដៅលើកស្ទួយសុខុមាលភាពរបស់មនុស្សចាស់ឲ្យបានល្អប្រសើរឡើង

-អត្រាមនុស្សចាស់ដែលមានអាយុចាប់ពី ៦០ឆ្នាំឡើងទៅមាន ៦,៣%នៃប្រជាជនសរុប។ អត្រានេះអាចមាននិន្នាការកើនឡើងជាបន្តបន្ទាប់ស្របតាមការរីកចម្រើននៃវិស័យសុខុមាលភាពសង្គម និងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ

-បានបង្កើតគណៈកម្មាធិការជាតិកម្ពុជាដើម្បីមនុស្សចាស់ និងយន្តការថ្នាក់ក្រោមជាតិសម្រាប់អនុវត្តគោលនយោបាយចំពោះមនុស្សចាស់ ។ ជារៀងរាល់ឆ្នាំស្របតាមសេចក្តីសម្រេចរបស់អង្គការសហប្រជាជាតិ ក្រសួង ស.អ.យ បានរៀបចំទិវាមនុស្សចាស់ ១តុលា ដើម្បីជាបុព្វហេតុក្នុងការគោរពដឹងគុណមនុស្សចាស់ និងលើកកម្ពស់មនសិការរបស់បងប្អូនជនរួមជាតិយើងទាំងអស់ ឲ្យចូលរួមកាន់តែសកម្មដើម្បីឲ្យកូនចៅជំនាន់ក្រោយៗទៀតមើលឃើញពីតម្លៃតតគណនារបស់មនុស្សចាស់។ ជារួម ប្រវត្តិសាស្ត្រ និងបទពិសោធន៍នៃសង្គមនីមួយៗ បានបង្ហាញឲ្យឃើញថា ការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌នៃប្រជាជាតិមួយ អាចប្រព្រឹត្តទៅបានប្រកបដោយចីរភាព និងសីលធម៌ ទាមទារឲ្យមានការអភិវឌ្ឍផ្នែកអប់រំសីលធម៌ គុណធម៌ និងវប្បធម៌អហិង្សា។ ផ្ទុយទៅវិញ ក្នុងសង្គមជាតិមួយដែលមានគុណធម៌ និងសីលធម៌ធ្លាក់ចុះ សង្គមជាតិនោះ នឹងត្រូវទទួលរងនូវវិបត្តិ និងមហន្តរាយ។ ព្រះរាជាណាចក្រកម្ពុជាយើងមានប្រពៃណី ទំនៀមទម្លាប់ដ៏ល្អ កេរ្តិ៍មរតកសម្បត្តិវប្បធម៌ដ៏សម្បូរបែប និងសមិទ្ធផលទាំងឡាយ ហើយត្រូវបានរក្សាគង់រង់រហូតមកដល់សព្វថ្ងៃនេះ។ មរតកទាំងអស់នេះកើតចេញពីស្នាដៃ គុណូបការៈ និងការអប់រំប្រៀនប្រដៅប្រកបដោយគតិបណ្ឌិតនៃបុព្វបុរស និងចាស់ព្រឹទ្ធាចារ្យរបស់យើង ដែលអាចជាក្សត្រ រាស្ត្រ មន្ត្រីរាជការ យុទ្ធជនបព្វជិត គ្រហស្ថ អ្នកអក្សរសាស្ត្រ ភាសាវិទូ សេដ្ឋកិច្ចវិទូ អ្នកស្រាវជ្រាវ សិល្បករ អ្នកច្បាប់ និងអ្នកវិទ្យាសាស្ត្រជាដើម។ ជាក់ស្តែង នៅឆ្នាំ២០១៣ ក្រសួងបានប្រារព្ធទិវាមនុស្សចាស់ក្រោមប្រធានបទ "**គោរពដឹងគុណមនុស្សចាស់ គឺជា កតញ្ញូតាធម៌ គ្រួសារមានសុភមង្គល សង្គមរីកចម្រើន**"

-ការប្រារព្ធទិវាមនុស្សចាស់បានជំរុញឲ្យគ្រប់ក្រសួង ស្ថាប័ន ព្រមទាំងអាជ្ញាធរមានសមត្ថកិច្ចគ្រប់លំដាប់ថ្នាក់ ឲ្យបង្កើនការយកចិត្តទុកដាក់ និងគាំទ្រគ្រប់មធ្យោបាយ នៅពេលចុះបំពេញការងារតាមមូលដ្ឋាន សូមឆ្លៀតសួរសុខទុក្ខ ជួយឧបត្ថម្ភដល់ជនចាស់ជរា ជាពិសេស ជនចាស់ជរាពិការដែលមានការលំបាកនៅក្នុងសហគមន៍។ អំពើល្អ និងកាយវិការដ៏ល្អប្រពៃដែលខ្លួនយើងបានធ្វើទៅលើអ្នកដទៃ គឺប្រៀបដូចជាការជួយខ្លួនឯង ពីព្រោះ កាយវិការដ៏ល្អនេះបានធ្វើចំពោះមនុស្សជំនាន់មុន គឺពិតជាបានបន្សល់ទុកឲ្យកូនចៅជំនាន់ក្រោយរបស់យើងបានរៀនសូត្រ និងត្រងត្រាប់តាម ដែលយើងនឹងទទួលបាននូវភាពកក់ក្តៅ ពោរពេញដោយក្តីសង្ឃឹម និងជឿជាក់ថា កូនចៅជំនាន់ក្រោយរបស់យើងនឹងជួយទំនុកបម្រុងដល់យើងបានល្អ ដូចដែលយើងបានទំនុកបម្រុងដល់មនុស្សចាស់ជំនាន់មុនដែរ។ ក្នុងឱកាសនៃទិវានេះដែរ បានអំពាវនាវឲ្យមនុស្សចាស់ សាស្ត្រចារ្យ លោកគ្រូ អ្នកគ្រូ នៅតាមគ្រឹះស្ថានឧត្តមសិក្សា និងសាលាចំណេះដឹងទូទៅទាំងអស់សូមបន្តយកចិត្តទុកដាក់ផ្តល់ការអប់រំសីលធម៌ ចរិយាធម៌ សុជីវធម៌ គុណធម៌ និងប្រពៃណីទំនៀមទម្លាប់ល្អៗដល់និស្សិត និងសិស្សានុសិស្សគ្រប់រូប ឲ្យចេះគោរពចាស់ព្រឹទ្ធាចារ្យនៅកម្ពុជា ជាអ្នកមានពិសោធន៍ជីវិត និងហែលឆ្លងនូវ

ទុក្ខលំបាក កើតចេញពីជម្លោះបែកបាក់ និងសង្គ្រាម ដែលកម្ពុជាហែលឆ្លងអស់ជាច្រើនទសវត្ស ហើយសូមកុំឲ្យក្មេងៗជំនាន់ក្រោយដើរធ្លាក់ទៅក្នុងគន្លងនៃការបែកបាក់នេះបន្តទៅទៀត។

-បាននិងកំពុងអនុវត្តនូវកម្មវិធីពីរជាសំខាន់គឺ: ទី១-ក ម្មវិធីអភិវឌ្ឍមនុស្សចាស់តាមសហគមន៍ និងទី២-កម្មវិធីថែទាំមនុស្សចាស់តាមគ្រួសារ និងសហគមន៍។ កម្មវិធីនេះបានជួយមនុស្សចាស់ឲ្យមានសុខភាពល្អ ដើម្បីរួមចំណែកក្នុងការអភិវឌ្ឍសហគមន៍ដែលពួកគាត់រស់នៅ

-បានបង្កើតសមាគមមនុស្សចាស់នៅតាមឃុំ សង្កាត់ដើម្បីថែរក្សាឧត្តមប្រយោជន៍ និងគាំទ្រដល់ស្ថានភាពជីវភាពរស់នៅរបស់មនុស្សចាស់។ មនុស្សចាស់ និងទុរគតជនបានទទួលនូវការឧបត្ថម្ភ គាំទ្រដោយក្រសួង ស្ថាប័ន មានសមត្ថកិច្ច អាជ្ញាធររដ្ឋបាលថ្នាក់ក្រោមជាតិ កាកបាទក្រហមកម្ពុជា សម្បុរសជននានា អង្គការមិនមែនរដ្ឋាភិបាលក្នុងសកម្មភាពប្រកបដោយសប្បុរសធម៌ ហើយបានឆ្លុះបញ្ចាំងឲ្យឃើញនូវវប្បធម៌ជួយឧបត្ថម្ភ គាំទ្រគ្នា និងការរួបរួមគ្នាជួយជ្រោមជ្រែងដោះស្រាយនូវទុក្ខលំបាករបស់ជនរួមជាតិ ជាពិសេសជនចាស់ជរា ជនពិការ និងទុរគតជន នៅក្នុងសង្គមជាតិយើង។ ជាមួយគ្នានេះ ស្ថានីយ៍វិទ្យុ និងទូរទស្សន៍ បាយ័នបានបង្កើតកម្មវិធីផ្ទះទេវតា ដើម្បីសាងសង់ផ្ទះជូនជនចាស់ជរាបានរាប់រយខ្នងនាពេលកន្លងមក។ បច្ចុប្បន្ន សមាគមមនុស្សចាស់មានចំនួន ៥៦៩សមាគម (កើន ៦៩) ដែលមានសមាជិកសរុបប្រមាណ ១៨៣.៤៣១នាក់ ដែលតាមរយៈសកម្មភាពសមាគមបានបង្កើតឲ្យមានកម្មវិធីថែទាំសុខភាព ធនាគារស្រូវ បេឡាមរណាសង្គ្រោះ និងការសាមគ្គីជួយគ្នាទៅវិញទៅមករវាងមនុស្សចាស់ដូចគ្នានៅក្នុងសហគមន៍

-បានអនុវត្ត និងពង្រីកកម្មវិធីថែទាំមនុស្សចាស់តាមគ្រួសារ និងតាមសហគមន៍ ស្របតាមប្រពៃណីទំនៀមទម្លាប់ល្អរបស់គ្រួសារខ្មែរ ក្នុងការគោរពដឹងគុណចំពោះមនុស្សចាស់រួមមាន ឪពុក ម្តាយ ជីដូន ជីតា និងជនចាស់ជរាគ្មានទីពឹង

-បានលើកទឹកចិត្តដល់សហគមន៍ អារាមសាសនា ជាពិសេសព្រះពុទ្ធសាសនា និងសាសនាដទៃទៀត ក្នុងការជួយដល់សាសនិកដែលជាជនចាស់ជរាបានជ្រកកោននៅតាមទីអារាម

-បានទទួលការគាំទ្រពីរាជរដ្ឋាភិបាល ឥស្សរជន និងសប្បុរសជននានា ក្នុងការរៀបចំនូវកម្មវិធីមនុស្សធម៌ដើម្បីផ្តល់អំណោយជា សម្ភារៈ និងថវិកាជួយដល់ជនចាស់ជរានៅតាមសហគមន៍ជាច្រើន។

៥-អភិវឌ្ឍរបបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល

-បានអនុវត្តគោលនយោបាយជាតិចំពោះអតីតមន្ត្រីរាជការស៊ីវិល ជាការដឹងគុណចំពោះគុណបំណាច់របស់អតីតមន្ត្រីរាជការស៊ីវិល ដែលបានរួមចំណែកក្នុងបុព្វហេតុ នៃការអភិវឌ្ឍប្រទេសជាតិ ហើយបានបន្សល់ទុកនូវស្នាដៃ និងបទពិសោធន៍ល្អៗ សម្រាប់មនុស្សជំនាន់ក្រោយៗទៀត ដោយបានផ្តល់នូវការលើកទឹកចិត្ត តាមរយៈការផ្តល់នូវកិត្តិយស សេចក្តីថ្លៃថ្នូ និងការផ្តល់នូវរបបសន្តិសុខសង្គម ដែលមានការកែសម្រួលជាបន្តបន្ទាប់ស្របតាមលទ្ធភាពនៃសេដ្ឋកិច្ចជាតិ

-បានរៀបចំ និងជំរុញដាក់ឲ្យដំណើរការនូវរបបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ដោយគ្របដណ្តប់លើតាវកាលិកចំនួន ៦ រួមមាន ការចូលនិវត្តន៍ ការបាត់បង់សម្បទាវិជ្ជាជីវៈ មាតុភាព គ្រោះថ្នាក់ការងារ មរណៈភាព និងអ្នកនៅក្នុងបន្ទុក នៃជនទាំងនេះ

-បានរៀបចំ និងអនុវត្តមាតិកាគណនី នៃប្លង់គណនេយ្យរបស់ ប.ជ.ស. ស្របតាមប្រកាសលេខ ១៥០២ សហវ.ប្រក ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៣ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ជាពិសេសលើការគ្រប់គ្រងហិរញ្ញវត្ថុសម្រាប់ដំណើរការគ្រប់យន្តការ នៃ ប.ជ.ស. ឲ្យមានគណនេយ្យភាព ប.ជ.ស. បានសុំការអនុញ្ញាត ទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីឲ្យសវនករឯករាជ្យធ្វើការត្រួតពិនិត្យ និងផ្តល់ទិដ្ឋាការលើរបាយការណ៍ ហិរញ្ញវត្ថុប្រចាំឆ្នាំ ចាប់ពីឆ្នាំ២០១៣តទៅ

-បានធ្វើបច្ចុប្បន្នភាពនិវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ ដែលជាអតីតមន្ត្រីរាជការស៊ីវិល និងអ្នកនៅក្នុងបន្ទុកចាស់-ថ្មី ជាបន្តបន្ទាប់ គ្រប់ក្រុង ស្រុក ខណ្ឌ នៅរាជធានី ខេត្ត ដើម្បីដាក់ឲ្យដំណើរការបម្រើសេវាបើកផ្តល់របបសន្តិសុខសង្គមតាមប្រព័ន្ធធនាគារនៅទូទាំងប្រទេស ចាប់ពីខែកុម្ភៈ ឆ្នាំ២០១៤ តទៅ

-ដើម្បីអនុវត្តស្របតាមស្មារតីនៃសារាចររបស់រាជរដ្ឋាភិបាលលេខ ០៤ សរ. ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ ២០១៤ ប.ជ.ស. បានបម្រើសេវាបើកផ្តល់របបសន្តិសុខសង្គមប្រចាំខែតាមប្រព័ន្ធធនាគារ ចាប់ពីខែសីហា ឆ្នាំ ២០១៤ បានទាន់ពេលវេលានៅគ្រប់រាជធានី ខេត្ត

-របបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ត្រូវបានដំឡើងជារៀងរាល់ឆ្នាំស្របតាមការដំឡើងបៀវត្សមន្ត្រីរាជការស៊ីវិល គិតមកដល់ឆ្នាំ២០១៤ កើនឡើងដល់ ២៣៥% នៃប្រាក់បៀវត្សមូលដ្ឋាន។ បច្ចុប្បន្នមាននិវត្តជន ចំនួន ៤១.០៦៨នាក់ និងជនបាត់បង់សម្បទាវិជ្ជាជីវៈ ចំនួន ២.៩៦២នាក់ និងអ្នកនៅក្នុងបន្ទុក ចំនួន ៤៥.៦៧០នាក់កំពុងទទួលរបបសន្តិសុខសង្គម។ នៅឆ្នាំ២០១៤នេះ រាជរដ្ឋាភិបាលបានចេញអនុក្រឹត្យ លេខ ២២១ អនក្រ.បក ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៤ ស្តីពីការបន្ថែមប្រាក់សោធនប្រចាំខែជូននិវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ ដែលជាអតីតមន្ត្រីរាជការស៊ីវិលតាមប្រភេទក្របខ័ណ្ឌ រួមមាន ប្រភេទ “ក” ចំនួន ២០.000រៀល -ប្រភេទ “ខ” ចំនួន ២០.000រៀល -ប្រភេទ “គ” ចំនួន ៤០.000រៀល -ប្រភេទ “ឃ” ចំនួន ៦០.000រៀល អនុវត្តចាប់ពីថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៤នេះ តទៅ

-បានពង្រឹង និងអភិវឌ្ឍគ្រឹះស្ថាន ប.ជ.ស. ដើម្បីបម្រើសេវាជូនសិទ្ធិវន្តនៃ ប.ជ.ស. ដោយបានរៀបចំរចនាសម្ព័ន្ធរដ្ឋបាល និងការប្រព្រឹត្តទៅ របស់ ប.ជ.ស. តាមសេចក្តីសម្រេចលេខ ១០៧ ក្រ/ប.ជ.ស. ចុះថ្ងៃទី ១៨ ខែកញ្ញា ឆ្នាំ២០១៤ របស់ក្រុមប្រឹក្សាភិបាលនៃ ប.ជ.ស. សម្រាប់បម្រើការងារ ប្រចាំថ្ងៃគ្រប់យន្តការនៅថ្នាក់កណ្តាល ថ្នាក់សាខាគ្រប់ក្រុង ស្រុក ខណ្ឌ នៅរាជធានី ខេត្តទូទាំងប្រទេស ឲ្យទទួលបានលទ្ធផលប្រកបដោយប្រសិទ្ធភាព

-រាជរដ្ឋាភិបាលក្រោមការងារដឹកនាំរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា បានសម្រេចផ្តល់ប្រាក់ភាគទាន ៦ ភាគរយ ជំនួសមន្ត្រីរាជការស៊ីវិលរហូតដល់ឆ្នាំ២០១៨ ក្នុងករណីដែលសម្តេចតេជោ **ហ៊ុន សែន** ជានាយករដ្ឋមន្ត្រី។ ដោយឡែក រាជរដ្ឋាភិបាលបានសម្រេចជាគោលការណ៍ ប្រគល់ការកិច្ចជូន រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ធ្វើជាសហប្រធានដឹកនាំរៀបចំប្រកាសអន្តរក្រសួងអាណាព្យាបាលនៃ ប.ជ.ស. ស្តីពីការអនុវត្តអត្រាភាគទានសម្រាប់ជាមូលនិធិទ្រទ្រង់បេឡាជាតិសន្តិសុខសង្គមមន្ត្រីរាជការស៊ីវិល ដើម្បីអនុវត្តស្របតាមស្មារតីនៃអនុក្រឹត្យលេខ ៧៣ អនក្រ.បក ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១។

៦-អភិវឌ្ឍសុខុមាលភាពអតីតយុទ្ធជន

-ការងារអតីតយុទ្ធជន និងគ្រួសារអតីតយុទ្ធជន ត្រូវបានយកចិត្តទុកដាក់អនុវត្តស្របតាមគោលនយោបាយជាតិ ដោយការគោរពដឹងគុណចំពោះគុណូបការៈដ៏ថ្លៃថ្លារបស់អតីតយុទ្ធជន និងគ្រួសារ ដែលបានធ្វើពលីកម្ម បូជាសាច់ស្រស់ ឈាមស្រស់ ដើម្បីបុព្វហេតុជាតិមាតុភូមិ និងប្រជាជន

-ជាក់ស្តែង ក្រសួង ស.អ.យ បានយកចិត្តទុកដាក់ចំពោះស្ថានភាពរបស់អតីតយុទ្ធជន និងគ្រួសារ ដូចតទៅ៖

- ○ បានអនុវត្តរបបសន្តិសុខសង្គមជូនអតីតយុទ្ធជនគ្រប់ដណ្តប់លើការការលិកចំនួន ៩ រួមមាន ការចូលនិត្តន៍ ការបាត់បង់សមត្ថភាពការងារ មាតុភាព អាពាហ៍ពិពាហ៍គ្រាដំបូង ពលី មរណៈ ពិការភាព ជំងឺ និងគ្រួសារទាំងនោះ
- ○ កែសម្រួលបន្ថែបរបបឧបត្ថម្ភជូនអតីតយុទ្ធជនជាបន្តបន្ទាប់ ស្របតាមសភាពការណ៍ជាក់ស្តែងនៃស្ថានភាពសេដ្ឋកិច្ចជាតិ គិតត្រឹមឆ្នាំ២០១៣ ប្រាក់បង្កើនភាគរយបានកើនឡើងដល់ ២៣៥%នៃប្រាក់បៀវត្សហានន្តរស័ក្តិ

- កែសម្រួលបង្កើនប្រាក់ឧបត្ថម្ភប្រចាំខែជូនឪពុក ម្តាយ អាណាព្យាបាលរបស់ជនពលី មរណៈ ពី៣.២០០រ ទៅ ៨.០០០រ ក្នុង ១ខែ
- កែសម្រួលប្រាក់បៀវត្សមូលដ្ឋាន និងប្រាក់ម្ហូបអាហារជូនជនពិការ និវត្តជន និងជនបាត់បង់សមត្ថភាពការងារ ដែលបានផ្ទេរមកក្រសួង ស.អ.យ មុន និងក្រោយឆ្នាំ២០០៧ ឲ្យមានតុល្យភាពគ្នា
- ការធ្វើបច្ចុប្បន្នភាពអតីតយុទ្ធជន និងគ្រួសារដើម្បីគ្រប់គ្រងតាមប្រព័ន្ធព័ត៌មានវិទ្យាបានបញ្ចប់ទាំងស្រុងក្នុងខែមិថុនា ឆ្នាំ២០១៤ ដោយបានលុបអតីតយុទ្ធជន និងអ្នកនៅក្នុងបន្ទុកដែលផុតចេញពីបញ្ជីបើកប្រាក់

-គិតមកដល់ខែសីហា ឆ្នាំ២០១៤នេះ អតីតយុទ្ធជនដែលកំពុងទទួលរបបសន្តិសុខសង្គមមានចំនួន ៩១.៥៥៩នាក់ និងអ្នកនៅក្នុងបន្ទុកចំនួន ១៧៥.៨៦៣នាក់ ហើយដំណើរការបើកផ្តល់របបតាមប្រព័ន្ធធនាគារ បានទាំងស្រុងនៅទូទាំងរាជធានី ខេត្តទាំង ២៥ សំដៅបង្កើនប្រសិទ្ធភាព គម្លាភាព និងទាន់ពេលវេលា

-បានអនុវត្តគោលការណ៍ ស្តីពីការកំណត់អត្តសញ្ញាណកងកម្លាំងប្រដាប់អាវុធចូលនិវត្តន៍ ចូលបាត់បង់សមត្ថភាពការងារ ពិការ និងគ្រួសារយុទ្ធជនពលី មរណៈ ដែលត្រូវទទួលសម្បទានដីសង្គមកិច្ច

-បានបន្តអនុវត្តគម្រោងអភិវឌ្ឍន៍សហគមន៍អតីតយុទ្ធជននៅតាមឃុំ សង្កាត់ ដែលក្នុងនោះ មានចំនួន ៦២ឃុំ សង្កាត់ នៅក្នុងរាជធានី ខេត្តចំនួន ២៥ កែលម្អជីវភាពរស់នៅរបស់អតីតយុទ្ធជន និងគ្រួសារ ឲ្យកាន់តែប្រសើរឡើងជាបន្តបន្ទាប់

-ក្រសួង ស.អ.យ សហការជាមួយសមាគមអតីតយុទ្ធជនកម្ពុជា (ស.អ.ក) បានរៀបចំប្រារព្ធខួបលើកទី៧ ទិវាអតីតយុទ្ធជនកម្ពុជា២១ មិថុនា ឆ្នាំ២០១៤ ដែលមានសមាសភាពចូលរួមពីថ្នាក់ដឹកនាំ មន្ត្រីរាជការក្រសួង ស.អ.យ និងអតីតយុទ្ធជនដែលបានអញ្ជើញមកពីរាជធានី ខេត្តទាំង ២៥ ចំនួនប្រមាណ ៣០០នាក់

-សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិតបានកសាងតំបន់អភិវឌ្ឍន៍យោធិនពិការតាកែនកោះស្លា ស្រុកឈូក ខេត្តកំពត មណ្ឌលអភិវឌ្ឍន៍យោធិនពិការ ៣១៧ ស្រុកគូលែន ខេត្តសៀមរាប និងមណ្ឌលអភិវឌ្ឍន៍យោធិនពិការភ្នំឆ័ត្រ ខេត្តបន្ទាយមានជ័យ និងឈានទៅកសាងនៅតំបន់ដទៃមួយចំនួនទៀត

-សមាគមអតីតយុទ្ធជនកម្ពុជា និងសប្បុរសជនបានសាងសង់ផ្ទះជូនអតីតយុទ្ធជន និងគ្រួសារ ក្នុងនាមសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត នៅតាមសហគមន៍បានចំនួន ២០១ខ្នង (កើនក្នុងឆ្នាំ២០១៣ ចំនួន ១៧ខ្នង) និងបន្តសាងសង់ជាបន្តបន្ទាប់ទៀតតាមលទ្ធភាពជាក់ស្តែង។

៧-សិក្សាស្រាវជ្រាវប្រព័ន្ធសន្តិសុខសង្គមទូលំទូលាយសម្រាប់ប្រជាជនកម្ពុជា

ក្រសួងបាន និងកំពុងសិក្សាស្រាវជ្រាវឯកសារនានា ដើម្បីរៀបចំបង្កើតប្រព័ន្ធសន្តិសុខសង្គមទូលំទូលាយសម្រាប់ប្រជាជនទូទៅ។

៨-អភិវឌ្ឍសមត្ថភាពស្ថាប័ន និងពង្រឹងភាពជាដៃគូ

-ក្រសួងបានពង្រឹង និងពង្រីកសកម្មភាពវិទ្យស្ថានជាតិសង្គមកិច្ច សំដៅបណ្តុះបណ្តាលធនធានមនុស្សសម្រាប់ស្ថាប័នរដ្ឋ វិស័យឯកជន និងអង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិ ដែលពាក់ព័ន្ធនឹងការងារសង្គមកិច្ច។ បច្ចុប្បន្ន វិទ្យាស្ថានកំពុងបណ្តុះបណ្តាលនិស្សិតកម្រិតឧត្តមសិក្សាចំនួន ១៧៩នាក់ ដែលសិក្សាលើជំនាញសង្គមកិច្ច សង្គមវិទ្យា វិស្វកម្មសិប្បនិម្មិតនិងរណប និងកិច្ចគាំពារសង្គម

-ការគ្រប់គ្រងឯកសារ និងការតម្កល់ឯកសារគតិយុត្តបានល្អត្រឹមត្រូវ

-រៀបចំការបែងចែកភារកិច្ចថ្នាក់ដឹកនាំ និងរបៀបរបបការងាររបស់ក្រសួង និងប្រកាសស្តីពីការពង្រឹងការអនុវត្តនីតិវិធីក្នុងការតែងតាំង ការផ្ទេរ និងការប្រគល់ភារកិច្ចមន្ត្រីរាជការក្រសួង

-បានតែងតាំង និងប្រគល់ភារកិច្ចជូនមន្ត្រីរាជការចំនួន ១០២នាក់ និងដាក់ឲ្យចូលនិវត្តន៍ចំនួន ៣៧នាក់។ រៀបចំបៀវត្សមូលដ្ឋានជូនមន្ត្រីក្របខ័ណ្ឌប្រភេទ គ ឃ តាមគោលការណ៍ចំនួន ១៥៩នាក់។ រៀបចំប្តូរក្របខ័ណ្ឌ ដំឡើងឋានន្តរស័ក្តិ និងថ្នាក់ចំនួន ១.០៣១នាក់ និងនិយតកម្មបៀវត្ស៍ចំនួន ២៥៧នាក់

-ក្របខ័ណ្ឌមន្ត្រីរាជការសរុបចំនួន ១.៥៨៥នាក់ ក្នុងនោះ នៅថ្នាក់ជាតិចំនួន ៥៩៥នាក់ និងថ្នាក់ក្រោមជាតិចំនួន ៩៩០នាក់

-បញ្ជូនមន្ត្រីរាជការទៅបណ្តុះបណ្តាលជំនាញបង្កើនសមត្ថភាពក្នុងប្រទេសចំនួន ២៨នាក់ និងក្រៅប្រទេសចំនួន ០១នាក់

-បានអនុវត្តកម្មវិធីកំណែទម្រង់របស់រាជរដ្ឋាភិបាលយ៉ាងសកម្ម ក្នុងនោះមានកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ដោយបានសិក្សាស្រាវជ្រាវកំណត់នូវមុខងារ និងធនធានរបស់ក្រសួង ស.អ.យ សម្រាប់ផ្ទេរទៅឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិជាជំហានៗសាកល្បងចាប់ពីឆ្នាំ២០១៤នេះ ។ កម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការអនុវត្តគោលនយោបាយបៀវត្ស៍សម្រាប់មន្ត្រីរាជការ និងប្រាក់បំណាច់ផ្សេងៗបានបើកផ្តល់ដោយត្រឹមត្រូវ និងទាន់ពេលវេលាទៅតាមប្រព័ន្ធធនាគារ

-បានរៀបចំ និងប្រកាសដាក់ឲ្យអនុវត្តផែនការយុទ្ធសាស្ត្រ ២០១៤-២០១៨ របស់ក្រសួង ស.អ.យ

-ក្រសួងបានលើកទឹកចិត្ត និងសហប្រតិបត្តិការជាមួយអង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិ និងដៃគូអភិវឌ្ឍនានា ក្នុងស្មារតីសាមគ្គីធម៌ និងកៀរគរប្រភពធនធានទាំងសម្ភារៈ ថវិកា និងបច្ចេកទេស បម្រើឲ្យសំណូមពររបស់ជនរងគ្រោះ និងងាយរងគ្រោះគ្រប់ប្រភេទក្នុងសង្គម។ ទន្ទឹមនេះ ក៏បានធ្វើសហប្រតិបត្តិការយ៉ាងជិតស្និទ្ធទាំងក្នុងក្របខ័ណ្ឌតំបន់ អាស៊ាន និងពិភពលោកពាក់ព័ន្ធនឹងវិស័យសុខុមាលភាពសង្គម និងការអភិវឌ្ឍ

-បានចេញសេចក្តីជូនដំណឹងដល់អង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិ ដែលមានបំណងធ្វើកិច្ចសហប្រតិបត្តិការជាមួយក្រសួង ស.អ.យ ក្នុងការបំពេញបែបបទ ឯកសារ និងនីតិវិធី។ បានប្រជុំពិភាក្សាលើខ្លឹមសារនៃកិច្ចព្រមព្រៀងដែលអង្គការបានបន្តកិច្ចសហប្រតិបត្តិការជាថ្មីបានចំនួន ៣១អង្គការ លើចំនួនអង្គការសរុបចំនួន ១៤១អង្គការ ដែលកំពុងធ្វើកិច្ចសហប្រតិបត្តិការជាមួយក្រសួង ស.អ.យ

-បានចុះអធិការកិច្ចដើម្បីពិនិត្យ កែលម្អការបំពេញមុខងារ តួនាទី របៀបរបបការងារនៅមន្ទីរ ស.អ.យ ខេត្តកំពត កែប ព្រះសីហនុ កំពង់ស្ពឺ កំពង់ឆ្នាំង បាត់ដំបង ប៉ៃលិន ព្រៃវែង ស្វាយរៀង កោះកុង និងខេត្តពោធិ៍សាត់ និងដោះស្រាយវិវាទផ្ទៃក្នុងចំនួន ០១ករណី

-ក្រុមការងារអ្នកនាំពាក្យ និងប្រតិកម្មរហ័សរបស់ក្រសួង ស.អ.យ ត្រូវបានបង្កើតឡើងដើម្បីពិនិត្យតាមដាន និងបកស្រាយបំភ្លឺរាល់ព័ត៌មានទាំងឡាយណាដែលពាក់ព័ន្ធការងារសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។ ក្រុមការងារនេះបានឆ្លើយបំភ្លឺទៅវិទ្យុ ABC ចំនួន ០៧ករណី ឆ្លើយតបជាមួយកាសែតខេមបូឌាដាលី ០១ករណី។ ទន្ទឹមនេះ ក្រុមការងារនេះ បានដោះស្រាយបញ្ហាសង្គមមួយចំនួន ដូចជា បានចាត់ចែងដោះស្រាយបញ្ហាស្ត្រីក្រីក្រមានកូន ៥នាក់ ដែលផ្ទះបាក់ចូលទន្លេហើយមកស្នាក់នៅចេតិយក្នុងវត្តនៅស្រុកស្អាង ខេត្តកណ្តាល ស្ត្រីមានវិបត្តិផ្លូវចិត្តយកកូនដាក់ចោលនៅវត្តក្នុងក្រុងក្រចេះ ខេត្តក្រចេះ កុមារត្រូវម្តាយដាក់ច្រវាក់ជើងនៅខេត្តកោះកុង ជនវិកលចរិតនៅតាមផ្លូវសាធារណៈនៅរាជធានីភ្នំពេញ បញ្ហាមណ្ឌលអង្គការនៅខេត្តប៉ៃលិន និងបញ្ហាក្មេងត្រូវគេធ្វើទារុណកម្មចាប់ជ្រមុជទឹកក្នុងពាងនៅស្រុកពារាំង ខេត្តព្រៃវែង

-បានរៀបចំសេចក្តីព្រាងផែនការយុទ្ធសាស្ត្រសវនកម្ម និងផែនការសកម្មភាពប្រចាំឆ្នាំ

-បានពង្រឹងសមត្ថភាពសវនករផ្ទៃក្នុង តាមរយៈ ការបញ្ជូនសវនករចូលរួមក្នុងកម្មវិធីបណ្តុះបណ្តាល និងសិក្ខាសាលានានា

-អនុវត្តតាមសេចក្តីសម្រេចស្តីពីការបង្កើតក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលកម្ពុជា ឯកឧត្តម **វង សូត** រដ្ឋមន្ត្រីក្រសួង ស.អ.យ បានដឹកនាំ និងចូលរួមវេទិកាសាធារណៈចំនួន ៥វេទិកា នៅវត្តជីនីក និងឃុំទ្រានៃស្រុកក្រូចឆ្មា វត្តវិហារលួងសង្កាត់សួងក្រុងសួង វត្តរកាពរជ្រាំនិងវត្តក្បាលបឹងសេះស្រុកត្បូងឃ្មុំ នៃខេត្តត្បូងឃ្មុំ។ ទន្ទឹមនេះ ឯកឧត្តម លោកជំទាវថ្នាក់ដឹកនាំ និងមន្ត្រីក្រសួងក៏បានចូលរួមវេទិកាសាធារណៈតាមខេត្តគោលដៅរៀងៗខ្លួនផងដែរ។ ក្នុងវេទិកានេះ ឯកឧត្តមរដ្ឋមន្ត្រីក៏ដូចឯកឧត្តម លោកជំទាវថ្នាក់ដឹកនាំក្រសួងបានស្រាយបំភ្លឺនូវចម្លល់ និងទទួលយកនូវសំណូមពររបស់បងប្អូនប្រជាជនដែលបានចូលរួមប្រកបដោយក្តីរីករាយ និងមោទនភាព។

៩-សេចក្តីសន្និដ្ឋាន

សមិទ្ធផលនៃវិស័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខាងលើនេះ បានរួមចំណែកក្នុងការអនុវត្តកម្មវិធីនយោបាយរបស់រដ្ឋាភិបាល និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។ តាមរយៈសមិទ្ធផលនេះ សុខុមាលភាពរបស់ប្រជាជន ជាពិសេស ជនរងគ្រោះ និងជនក្រីក្រងាយរងគ្រោះត្រូវបានអន្តរាគមន៍ជួយទាន់ពេលវេលា និងបានលើកកម្ពស់ជីវភាពស្របតាមការអភិវឌ្ឍនៃសេដ្ឋកិច្ចជាតិ។ ប្រព័ន្ធសន្តិសុខសង្គមក៏ត្រូវបានរៀបចំ និងចាប់ផ្តើមដំណើរការផ្តល់សេវាប្រកបដោយប្រសិទ្ធភាព និងសុទិដ្ឋិនិយម។ សេវាសង្គមកិច្ចត្រូវបានពង្រឹងពង្រីកតាមរយៈការកសាងលិខិតបទដ្ឋានគតិយុត្ត ការបណ្តុះបណ្តាលធនធានមនុស្ស និងការពង្រឹងអភិបាលកិច្ចល្អ។

ការពង្រឹងពង្រីកភាពជាដៃគូជាមួយដៃគូអភិវឌ្ឍ សង្គមស៊ីវិល អង្គការមិនមែនរដ្ឋាភិបាល សប្បុរសជន សហគមន៍បានកៀរគរប្រភពធនធានទាំងបច្ចេកទេស និងហិរញ្ញវត្ថុ បានយ៉ាងធំធេងរួមចំណែកក្នុងការដោះស្រាយបញ្ហាជីវភាពរស់នៅរបស់ប្រជាជននៅក្នុងសង្គម ជាពិសេសការងារមនុស្សធម៌

ទន្ទឹមនឹងសមិទ្ធផលសំខាន់ៗដែលសម្រេចបានឡើងខាងលើ យើងមានបញ្ហាប្រឈមមួយចំនួន រួមមាន ភាពក្រីក្រ គំលាតក្នុងចំណោមប្រជាជនរវាងអ្នកមាន និងអ្នកក្រ រវាងជនបទ និងទីក្រុង ការប្រែប្រួលអាកាសធាតុ ជំងឺរាតត្បាតចម្លែកៗ បញ្ហាជនអនាថា ការជួញដូរមនុស្ស ការប្រើប្រាស់គ្រឿងញៀន ការធ្លាក់ចុះនៃសីលធម៌ សុជីវធម៌។ល។ ដោយឡែកសម្រាប់ក្របខ័ណ្ឌក្រសួង ក៏មានកត្តាមួយចំនួន ជាអាទិ៍ កត្តាធនធានមនុស្សទាំងបរិមាណ និងគុណភាពនៅមានកម្រិត ការិយាល័យ ស.អ.យ ស្រុកមួយចំនួនមិនទាន់មានមន្ត្រីបម្រើការងារ។ សមត្ថភាពមន្ត្រីទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិនៅមានកម្រិត មន្ត្រីដែលមានសមត្ថភាពមួយចំនួនចេញទៅធ្វើការខាងក្រៅ។ កញ្ចប់ថវិការួមរបស់ក្រសួងចំនួន ៩៣%ជាប្រាក់បៀវត្សរ៍របស់មន្ត្រីរាជការ និងប្រាក់សោធនរបស់អតីតមន្ត្រីរាជការស៊ីវិល និងអតីតយុទ្ធជន។ ព្រមជាមួយនេះ ក្រសួងមិនមានមធ្យោបាយគ្រប់គ្រាន់សម្រាប់បំពេញការងារ។

II-ទិសដៅបន្តឆ្នាំ២០១៤-២០១៥ នៃវិស័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

ក-ចក្ខុវិស័យ

"បង្កើតសេវាសុខុមាលភាពសង្គមឲ្យជិតកៀកជនរងគ្រោះ និងងាយរងគ្រោះ និងពង្រឹងពង្រីកប្រព័ន្ធសន្តិសុខសង្គម" លើគោលការណ៍ អ្វីៗដើម្បីប្រសិទ្ធភាពនៃសេវាសង្គមកិច្ច។

ខ-គោលនយោបាយរួមនៃវិស័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងវិធានការអនុវត្ត

យកចិត្តទុកដាក់ដល់ការអភិវឌ្ឍវិស័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ឲ្យកាន់តែទូលំទូលាយថែមទៀត ដើម្បីធ្វើឲ្យសុខុមាលភាពរបស់ប្រជាជនបានកាន់តែល្អប្រសើរ មានសេវាសង្គមកិច្ចគ្រប់គ្រាន់សម្រាប់ជួយដល់ជនរងគ្រោះ និងងាយរងគ្រោះគ្រប់ប្រភេទ មានប្រព័ន្ធសន្តិសុខសង្គមរឹងមាំ និងទូលំ

ទូលាយសម្រាប់ធានារ៉ាប់រងដល់ហានិភ័យសង្គមជាយថាហេតុរបស់ប្រជាជនគ្រប់មជ្ឈដ្ឋាន និងធានានូវការបង្កើតសេវាសង្គមកិច្ច ទៅកៀកនឹងប្រជាជន និងដោយមានការចូលរួមពីប្រជាជន។ ខិតខំកៀរគរប្រមូលធនធានជាតិ ដៃគូអភិវឌ្ឍន៍ និងសប្បុរសជននានា ដើម្បីបង្កើនធនធានបច្ចេកទេស និងហិរញ្ញវត្ថុសម្រាប់វិស័យសង្គមកិច្ច អតីតយុទ្ធជន យុវនីតិសម្បទា។

ដើម្បីសម្រេចទិសដៅនេះ ក្រសួងកំណត់យុទ្ធសាស្ត្រ ៣ គឺ ១-បង្កើនប្រសិទ្ធភាពសេវាសង្គមកិច្ច ២-ជំរុញដំណើរការប្រព័ន្ធសន្តិសុខសង្គម និង៣-កៀរគរប្រភពធនធានទាំងផ្នែកបច្ចេកទេសនិងហិរញ្ញវត្ថុ និងកម្មវិធីអាទិភាព ៨ ចំណុច ដូចខាងក្រោម៖

១-អភិវឌ្ឍសុខុមាលភាពសង្គម

-បង្កើនអន្តរាគមន៍សង្គមកិច្ច ដើម្បីជួយដល់ប្រជាជនក្រីក្រងាយរងគ្រោះ ជនរងគ្រោះដោយគ្រោះមហន្តរាយធម្មជាតិ ដោយមិនទុកឲ្យប្រជាជនណាម្នាក់ស្លាប់ដោយអត់បាយដែលយើងមិនបានដឹង ហើយមិនបានដោះស្រាយ

-បន្តពង្រីកកម្មវិធីសង្គ្រោះបន្ទាន់សម្រាប់ប្រជាជនក្រីក្រងាយរងគ្រោះ ទប់ស្កាត់ភាពងាយរងគ្រោះរបស់ប្រជាជនក្រីក្រនៅតាមសហគមន៍ ទប់ស្កាត់ទុរគតភាព ការធ្វើចំណាកស្រុកដោយប្រថុយប្រថាន។

-បន្តពង្រឹងកម្មវិធីដោះស្រាយបញ្ហាជនអនាថា ចាត់ទុកជនអនាថាជាជនរងគ្រោះដែលត្រូវទទួលបាននូវការគាំពារផ្នែកសង្គមកិច្ច ការផ្តល់សេវាជូនជនអនាថា ដោយឈរលើគោលការណ៍គោរពសិទ្ធិមនុស្ស និងការបង្កឱកាសឲ្យស្តារជីវភាពឡើងវិញ និងធ្វើសមាហរណកម្មទៅក្នុងសង្គម

-បន្តអភិវឌ្ឍចលនាគ្រួសារល្អ ទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ។ លើកកម្ពស់តួនាទីរបស់គ្រួសារ ជាកោសិការបស់សង្គម ជាកន្លែងផ្តល់ភាពកក់ក្តៅ និងសុភមង្គលសម្រាប់ប្រជាជនគ្រប់រូប រួមចំណែកក្នុងការអភិវឌ្ឍសង្គម។ បន្តចាត់តាំងទិវាអន្តរជាតិស្តីពីគ្រួសារ ១៥ ឧសភា និងបន្តផ្សព្វផ្សាយទស្សនាទានយេនឌ័រ និងអនុសញ្ញា ស៊ី-ដ

-ពង្រឹងការផ្តល់សេវាថែទាំ និងគាំទ្រដល់ជនរងគ្រោះ និងរងផលប៉ះពាល់ដោយសារមេរោគអេដស៍ ជំងឺអេដស៍ និងជំងឺកាចសាហាវផ្សេងៗ

-រៀបចំ និងអនុវត្តគោលនយោបាយស្តីពីការអភិវឌ្ឍសហគមន៍ប្រជាជនក្រីក្រនៅតាមសហគមន៍ ដើម្បីទទួលនូវកាលានុវត្តភាពសម្រាប់កែប្រែជីវភាព

-ជំរុញការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងការជួយដល់ជនរងគ្រោះ តាមរយៈការស្តារនីតិសម្បទា ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងធ្វើសមាហរណកម្មជនរងគ្រោះទៅសហគមន៍វិញដោយគ្មានការរើសអើង

-បន្តអនុវត្តគោលនយោបាយ បទដ្ឋានអប្បបរមាស្តីពីកិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស។

២-អភិវឌ្ឍសុខុមាលភាពកុមារ និងយុវនីតិសម្បទា

-ផ្តល់អាទិភាព ក្នុងការអភិវឌ្ឍសុខុមាលភាពកុមារដែលជាទំពាំងស្នងឫស្សី អ្នកបន្តវេនសម្រាប់អនាគតរបស់ប្រទេសជាតិ ដោយឈរលើមូលដ្ឋាន ការអភិវឌ្ឍលើគ្រប់វិស័យទាំងអស់ដែលកំពុងធ្វើសព្វថ្ងៃ ជាពិសេស វិស័យសុខុមាលភាពកុមារ គឺដើម្បីអនាគតរបស់កុមារ

-បន្តជំរុញផ្សព្វផ្សាយ និងអនុវត្តច្បាប់ គោលនយោបាយ បទដ្ឋាន គោលការណ៍ណែនាំដែលពាក់ព័ន្ធនឹងកិច្ចការពារកុមារ រួមនឹងអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិកុមារ ជាពិសេសសិទ្ធិជាមូលដ្ឋានទាំងបួនរបស់កុមារ គឺ "សិទ្ធិរស់រានមានជីវិត សិទ្ធិទទួលបាននូវការអភិវឌ្ឍ សិទ្ធិទទួលបាននូវការការពារ និងសិទ្ធិចូលរួមរបស់កុមារ" ឲ្យបានទូលំទូលាយទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ

-បន្តស្វែងរកការគាំទ្រ កៀរគរធនធាន និងបង្កើនកិច្ចសហការអនុវត្តប្រកបដោយជោគជ័យនូវគោលដៅអភិវឌ្ឍសហសវត្សដែលពាក់ព័ន្ធនឹងវិស័យកុមារ ជាអាទិ៍ លើវិស័យសុខាភិបាល ការកាត់បន្ថយ

អត្រាមរណភាពមាតា និងទារក អប់រំ ការបង្កើនអត្រាចូលរៀនរបស់សិស្ស និងគុណភាពអប់រំ។ល។ ជាពិសេស នៅតំបន់ដាច់ស្រយាល និងតំបន់ជនជាតិភាគិចរស់នៅ

-បន្តអនុវត្តប្រព័ន្ធសុខុមាលភាពកុមារ គោលនយោបាយថែទាំជំនួសចំពោះកុមារ បទដ្ឋានអប្បបរមាសម្រាប់ការថែទាំកុមារនៅក្នុងមណ្ឌល និងបទដ្ឋានអប្បបរមាសម្រាប់ថែទាំកុមារនៅតាមសហគមន៍។ ជំរុញការអនុវត្តប្រកាស ស្តីពីនីតិវិធីអនុវត្តគោលនយោបាយថែទាំជំនួសចំពោះកុមារដោយក្រសួង ស.អ.យ ធ្វើប្រតិភូកម្មជូនក្រុមប្រឹក្សារាជធានី ខេត្ត ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ និងក្រុមប្រឹក្សាឃុំ សង្កាត់នូវភារកិច្ចក្នុងវិស័យថែទាំចំពោះកុមារ។ ជ្រើសរើសឲ្យមានបុគ្គលិកវិជ្ជាជីវៈសង្គមកិច្ច សំដៅជំរុញការអនុវត្តគោលនយោបាយថែទាំជំនួស ការគ្រប់គ្រងករណី និងការធ្វើសមាហរណកម្មកុមារ និងបង្កើតឲ្យមានយន្តការ គណៈកម្មការគ្រប់គ្រងករណី និងការបង្រួបបង្រួមគ្រួសារកុមារចេញពីមណ្ឌលទៅគ្រួសារ និងសហគមន៍

-បន្តពង្រឹងគុណភាពនៃការថែទាំកុមារនៅតាមមណ្ឌល ទាំងមណ្ឌលរដ្ឋ និងអង្គការមិនមែនរដ្ឋាភិបាល តាមរយៈការធ្វើអធិការកិច្ច ការកសាងផែនទីមណ្ឌលថែទាំកុមារជាប្រព័ន្ធ ការធ្វើបច្ចុប្បន្នភាពកុមារ សំដៅកាត់បន្ថយចំនួនមណ្ឌលដែលអនុវត្តស្របតាមគោលនយោបាយ ស្តីពីការថែទាំជំនួសចំពោះកុមារ និងបទដ្ឋានអប្បបរមា ស្តីពីការថែទាំជំនួសចំពោះកុមារ លើកទឹកចិត្តការបង្រួបបង្រួមគ្រួសារកុមារ តាមគោលការណ៍ផ្តល់អាទិភាពឲ្យកុមារទទួលបានការអភិវឌ្ឍក្នុងក្របខ័ណ្ឌគ្រួសារ តាមគោលការណ៍ពង្រឹងគុណភាព កាត់បន្ថយបរិមាណមណ្ឌល

-បន្តជំរុញការផ្សព្វផ្សាយ និងអនុវត្តច្បាប់ ស្តីពីស្នំកូនអន្តរប្រទេស និងលិខិតបទដ្ឋានគតិយុត្តនានា ដើម្បីរួមចំណែកក្នុងការអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល ស្តីពីការលើកកម្ពស់សុខុមាលភាពកុមារឲ្យល្អប្រសើរ ដោយយកចិត្តទុកដាក់ក្នុងការទុកដាក់កុមារនៅក្នុងស្រុកឲ្យអស់លទ្ធភាព មុននឹងឈានដល់ដំណាក់កាលអនុវត្តការងារស្នំកូនអន្តរប្រទេសស្របតាមអនុសញ្ញាក្រុងឡាអេ ស្តីពីការការពារកុមារ និងសហប្រតិបត្តិការទាក់ទងស្នំកូនអន្តរប្រទេស ក្នុងគោលដៅមនុស្សធម៌សុទ្ធសាធ ដើម្បីរកគ្រួសារល្អឲ្យកុមារ និងធានាឧត្តមប្រយោជន៍របស់កុមារ

-បន្តពង្រឹង ពង្រីកកិច្ចសហប្រតិបត្តិការ ចុះកិច្ចព្រមព្រៀងស្តីពីការកំណត់ចំនួនទីភ្នាក់ងារស្នំកូនអន្តរប្រទេសជាមួយប្រទេសដែលជាភាគីអនុសញ្ញាក្រុងឡាអេ និងប្រទេសដែលមានកិច្ចសហប្រតិបត្តិការស្នំកូនអន្តរប្រទេសជាមួយព្រះរាជាណាចក្រកម្ពុជា ដើម្បីទប់ស្កាត់ការជួញដូរកុមារ តាមរូបភាពស្នំកូនអន្តរប្រទេស

-ជំរុញការអនុវត្តការងារយុវនីតិសម្បទា និងអនុវត្តកម្មវិធីយុត្តិធម៌អនីតិជន បន្តផ្តល់នូវសេវាការពារសិទ្ធិកុមារតាមផ្លូវច្បាប់ ចំពោះអនីតិជនដែលប្រព្រឹត្តល្មើសនឹងច្បាប់តាមសហគមន៍ តាមពន្ធនាគារ។ ជំរុញការអនុម័តសេចក្តីព្រាងច្បាប់ស្តីពីយុត្តិធម៌អនីតិជន ដើម្បីការពារសិទ្ធិកុមារនៅក្នុងប្រព័ន្ធយុត្តិធម៌ និងទប់ស្កាត់បាតុភាពអសកម្មរបស់អនីតិជន

-បន្តអនុវត្តគោលនយោបាយ ស្តីពីមជ្ឈមណ្ឌលព្យាបាល ស្តារនីតិសម្បទាសម្រាប់ជួយជនរងគ្រោះដែលប្រើបាស់បំពានសារធាតុញៀន ព្រមជាមួយនោះជំរុញគោលនយោបាយលើកទឹកចិត្ត ការព្យាបាល និងស្តារនីតិសម្បទាជនរងគ្រោះដែលប្រើប្រាស់បំពានសារធាតុញៀនតាមសហគមន៍ ដោយផ្តើមចេញពីការដកបទពិសោធន៍ជំហានដំបូង កម្មវិធីព្យាបាលនៅរាជធានីភ្នំពេញ មុននឹងឈានពង្រីកកម្មវិធីនេះនៅទូទាំងប្រទេស

-បន្តបញ្ចប់រាល់សេចក្តីព្រាងច្បាប់ អនុក្រឹត្យ ប្រកាស គោលការណ៍ណែនាំពាក់ព័ន្ធនៅសេសសល់ពាក់ព័ន្ធនឹងសុខុមាលភាពកុមារ

-បន្តអនុវត្តកាតព្វកិច្ចជាសមាជិកនៃការអនុវត្តអនុសញ្ញា ស្តីពីសិទ្ធិកុមារ រៀបចំ និងផ្ញើរបាយការណ៍ជាតិលើកទី៤ ដល់លើកទី៦ ស្តីពីការអនុវត្តអនុសញ្ញាសិទ្ធិកុមារ និងរបាយការណ៍ជាតិស្តីពីការអនុវត្តពិធីសារពាក់ព័ន្ធផ្សេងទៀត ជូនអង្គការសហប្រជាជាតិបានទាន់ពេលវេលាប្រកបដោយគុណភាព។

៣-អភិវឌ្ឍសុខុមាលភាពជនពិការ

-បន្តជំរុញការអនុវត្តច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ និងផែនការយុទ្ធសាស្ត្រជាតិ ស្តីពីពិការភាព ២០១៤-២០១៨ ដើម្បីលើកកម្ពស់សិទ្ធិ និងលុបបំបាត់ការរើសអើងចំពោះជនពិការ ព្រមទាំងបង្កឱកាសឲ្យជនពិការបានចូលរួមគ្រប់សកម្មភាពរបស់សង្គម

-បន្តជំរុញអនុវត្តអនុសញ្ញាអង្គការសហប្រជាជាតិ ស្តីពីសិទ្ធិជនពិការ និងទសវត្សរ៍ជនពិការប្រចាំតំបន់អាស៊ី និងប៉ាស៊ីហ្វិកឆ្នាំ២០១៣-២០២២ យុទ្ធសាស្ត្រអ៊ីនឈាន់ "ធ្វើឲ្យសិទ្ធិក្លាយជាការពិត"

-រៀបចំទិវាជនពិការកម្ពុជា ទិវាជនពិការអន្តរជាតិ និងទិវាផ្សេងៗទៀត សម្រាប់ជនពិការ

-បន្តអនុវត្តផែនការយុទ្ធសាស្ត្រ ២០១៤-២០១៨ របស់មូលនិធិជនពិការ និងកៀរគរប្រភពធនធានដើម្បីអភិវឌ្ឍមូលនិធិជនពិការ

-បន្តផ្តល់សេវាស្តារលទ្ធភាពពលកម្មកាយសម្បទាជូនជនពិការ សេវាព្យាបាលដោយចលនា សេវាស្តារលទ្ធភាពពលកម្មវេជ្ជសាស្ត្រ

-បន្តជំរុញការផ្តល់របបគោលនយោបាយចំពោះជនពិការក្រីក្រតាមសហគមន៍ ស្របតាមលទ្ធភាពថវិកាជាតិ

-បន្តសម្របសម្រួលអនុវត្តកម្មវិធីស្តារលទ្ធភាពពលកម្មនៅសហគមន៍ជូនជនពិការ និងបង្កើតក្រុមជួយខ្លួនឯងនៃជនពិការ

-បន្តបណ្តុះបណ្តាលវិជ្ជាជីវៈជនពិការ និងអភិវឌ្ឍមុខរបរខ្នាតតូចជូនជនពិការនៅតាមសហគមន៍

-បន្តជំរុញការផ្តល់ឱកាសជូនជនពិការចូលបម្រើការងារតាមក្រសួង ស្ថាប័នរដ្ឋ និងវិស័យឯកជនតាមអត្រាកំណត់

-បន្តពង្រឹងកម្មវិធីផ្តល់សេវាជូនកុមារពិការភ្នែក កុមារគរថ្លង់និងកុមារខ្សោយសតិបញ្ញា និងធ្វើសមាហរណកម្មកុមារពិការទៅក្នុងសហគមន៍

-បន្តលើកទឹកចិត្តចលនាកីឡា សិល្ប:របស់ជនពិការ ការងារព័ត៌មានជាភាសាសញ្ញា និងការអភិវឌ្ឍសេវាអក្សរស្ទាប និងភាសាសញ្ញា

-បន្តសហការជាមួយមជ្ឈមណ្ឌលអភិវឌ្ឍន៍ជនពិការប្រចាំតំបន់អាស៊ី និងប៉ាស៊ីហ្វិក អនុវត្តគម្រោងសាកល្បង ស្តីពីបរិស្ថានគ្មានពិការភាព។

៤-អភិវឌ្ឍសុខុមាលភាពមនុស្សចាស់

-រៀបចំកែសម្រួលអនុក្រឹត្យលេខ ១៥៨ អនក្រ.បក ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១១ ស្តីពីការបង្កើតគណៈកម្មាធិការជាតិកម្ពុជាដើម្បីមនុស្សចាស់ទៅជាព្រះរាជក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការជាតិកម្ពុជាដើម្បីមនុស្សចាស់វិញ

-បន្តអនុវត្តគោលនយោបាយជាតិសម្រាប់មនុស្សចាស់ និងរៀបចំកែសម្រួលបន្ថែមលើចំណុចដែលនៅខ្វះចន្លោះ ឲ្យស្របតាមស្ថានភាពសេដ្ឋកិច្ចជាតិ

-បន្តបង្កើតគណៈកម្មាធិការជាតិកម្ពុជាដើម្បីមនុស្សចាស់ និងយន្តការថ្នាក់ក្រោមជាតិសម្រាប់អនុវត្តគោលនយោបាយចំពោះមនុស្សចាស់ និងរៀបចំទិវាមនុស្សចាស់ ១ តុលា ក្រោមប្រធានបទ "**សមាគមមនុស្សចាស់ជាយន្តការដ៏សំខាន់ជួយអភិវឌ្ឍសហគមន៍ និងសង្គមជាតិ**"

-អនុវត្តនូវកម្មវិធីពីរជាសំខាន់គឺ: ទី១-កម្មវិធីអភិវឌ្ឍមនុស្សចាស់តាមសហគមន៍ និងទី២-កម្មវិធីថែទាំមនុស្សចាស់តាមគ្រួសារ

-បន្តគាំទ្រ និងលើកទឹកចិត្តក្នុងការបង្កើត គ្រប់គ្រង និងពង្រីកសមាគមមនុស្សចាស់តាមភូមិ ឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌ នៅគ្រប់រាជធានី ខេត្ត

-បន្តគាំទ្រ និងលើកទឹកចិត្តដល់សហគមន៍ អារាមសាសនា ជាពិសេសព្រះពុទ្ធសាសនា និងសាសនាដទៃទៀត ក្នុងការជួយដល់សាសនិកដែលជាមនុស្សចាស់ជរាបានជ្រកកោននៅតាមទីអារាម

-បន្តគាំទ្រ និងលើកទឹកចិត្តដល់ឥស្សរជន និងសប្បុរសជននានាក្នុងការរៀបចំនូវកម្មវិធីមនុស្សធម៌ ដើម្បីផ្តល់អំណោយជាសម្ភារៈ និងថវិកាជួយដល់ជនចាស់ជរានៅតាមសហគមន៍

-ជំរុញឲ្យមានការរៀបចំមជ្ឈមណ្ឌលសេវាជនចាស់ជរាកម្ពុជា

-ជំរុញការបណ្តុះបណ្តាលបុគ្គលិក ភ្នាក់ងារសង្គមកិច្ច ដើម្បីផ្តល់សេវាថែទាំជនចាស់ជរា

-លើកទឹកចិត្តអង្គការមិនមែនរដ្ឋាភិបាល ផ្នែកឯកជនបង្កើតសេវាថែទាំសុខភាពជនចាស់ជរា។

៥-អភិវឌ្ឍរបបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល

-បន្តអនុវត្តគោលនយោបាយជាតិចំពោះអតីតមន្ត្រីរាជការស៊ីវិល ជាការដឹងគុណចំពោះគុណបំណាច់របស់អតីតមន្ត្រីរាជការស៊ីវិល ដែលបានរួមចំណែកក្នុងបុព្វហេតុ នៃការអភិវឌ្ឍប្រទេសជាតិ ហើយបានបន្សល់ទុកនូវស្នាដៃ និងបទបិសោធន៍ល្អៗ សម្រាប់មនុស្សជំនាន់ក្រោយៗទៀត ដោយបន្តផ្តល់នូវការលើកទឹកចិត្ត តាមរយៈការផ្តល់នូវកិត្តិយស សេចក្តីថ្លៃថ្នូ និងការផ្តល់នូវរបបសន្តិសុខសង្គម ដែលមានការកែសម្រួលជាបន្តបន្ទាប់ស្របតាមលទ្ធភាពនៃសេដ្ឋកិច្ចជាតិ

-បន្តរៀបចំ និងជំរុញដាក់ឲ្យដំណើរការនូវរបបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ដែលរួមមានតាវកាលិក ៦មុខ រួមមាន ការចូលនិវត្តន៍ ការបាត់បង់សម្បទាវិជ្ជាជីវៈ មាតុភាព គ្រោះថ្នាក់ការងារ មរណភាព និងអ្នកនៅក្នុងបន្ទុក នៃជនទាំងនេះ

-បន្តអនុវត្តមាតិកាគណនី នៃប្លង់គណនេយ្យរបស់ ប.ជ.ស. ស្របតាមប្រកាសលេខ ១៥០២ សហវ.ប្រក ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៣ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ជាពិសេសលើការគ្រប់គ្រងហិរញ្ញវត្ថុ សម្រាប់ដំណើរការគ្រប់យន្តការ នៃ ប.ជ.ស. ឲ្យមានគណនេយ្យភាព ប.ជ.ស. បន្តសុំការអនុញ្ញាតទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីឲ្យសវនករឯករាជ្យធ្វើការត្រួតពិនិត្យ និងផ្តល់ទិដ្ឋាការលើរបាយការណ៍ ហិរញ្ញវត្ថុប្រចាំឆ្នាំ ចាប់ពីឆ្នាំ២០១៣តទៅ

-បន្តធ្វើបច្ចុប្បន្នភាពនិវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ ដែលជាអតីតមន្ត្រីរាជការស៊ីវិល និងអ្នកនៅក្នុងបន្ទុកចាស់-ថ្មី ជាបន្តបន្ទាប់ គ្រប់ក្រុង ស្រុក ខណ្ឌ នៅរាជធានី ខេត្ត ដើម្បីដាក់ឲ្យដំណើរការបម្រើសេវាបើកផ្តល់របបសន្តិសុខសង្គមតាមប្រព័ន្ធធនាគារ នៅទូទាំងប្រទេស

-ដើម្បីអនុវត្តស្របតាមស្មារតី នៃសារាចររបស់រាជរដ្ឋាភិបាលលេខ ០៤ សរ. ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៤ ប.ជ.ស. បន្តបម្រើសេវាបើកផ្តល់របបសន្តិសុខសង្គមប្រចាំខែតាមប្រព័ន្ធធនាគារជូនសិទ្ធិវន្ត នៃ ប.ជ.ស. នៅគ្រប់រាជធានី ខេត្ត ឲ្យបានទាន់ពេលវេលា

-បន្តពិនិត្យ និងសុំគោលការណ៍កែសម្រួលរបបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ស្របតាមលទ្ធភាពថវិកាជាតិ

-ពង្រឹង និងអភិវឌ្ឍគ្រឹះស្ថាន ប.ជ.ស. ដើម្បីបម្រើសេវារបបសន្តិសុខសង្គមសម្រាប់សិទ្ធិវន្ត នៃ ប.ជ.ស.. ដោយបន្តអនុវត្តរចនាសម្ព័ន្ធរដ្ឋបាល និងការប្រព្រឹត្តទៅរបស់ ប.ជ.ស. តាមសេចក្តីសម្រេចលេខ ១០៧/ប.ជ.ស. ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៤ របស់ក្រុមប្រឹក្សាភិបាល នៃ ប.ជ.ស. សម្រាប់បម្រើការងារប្រចាំថ្ងៃគ្រប់យន្តការនៅថ្នាក់កណ្តាល ថ្នាក់សាខាគ្រប់ក្រុង ស្រុក ខណ្ឌ នៅរាជធានី ខេត្តទូទាំងប្រទេស ឲ្យទទួលបានលទ្ធផលប្រកបដោយប្រសិទ្ធភាព

-បន្តតាមដានការអនុវត្តគោលការណ៍ ដែលបានសម្រេចដោយរាជរដ្ឋាភិបាលប្រគល់ភារកិច្ចជូនរដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ធ្វើជាសហប្រធានដឹកនាំរៀបចំប្រកាសអន្តរក្រសួងអាណាព្យាបាល នៃ ប.ជ.ស. ស្តីពីការអនុវត្តអត្រាភាគទានសម្រាប់ជាមូលនិធិទ្រទ្រង់បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល

-រាជរដ្ឋាភិបាលក្រោមការដឹកនាំរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជានឹងបន្តផ្តល់ប្រាក់ភាគទាន ៦ភាគរយ ជំនួសឲ្យមន្ត្រីរាជការស៊ីវិលរហូតដល់ឆ្នាំ ២០១៨ និងសម្រាប់អណាត្តិបន្តបន្ទាប់ទៀត ក្នុងករណីរាជរដ្ឋាភិបាល ដែលដឹកនាំដោយសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ជានាយករដ្ឋមន្ត្រី។

៦-អភិវឌ្ឍសុខុមាលភាពអតីតយុទ្ធជន

-បន្តយកចិត្តទុកដាក់រៀបចំប្រកាសផ្តល់របបសន្តិសុខសង្គមជូនអតីតយុទ្ធជន និងគ្រួសារថ្មីដែលផ្ទេរមកពីក្រសួងពាក់ព័ន្ធឲ្យបានទាន់ពេលវេលា តម្លាភាព និងការទទួលខុសត្រូវ

-បើកវគ្គបណ្តុះបណ្តាលកសាងសមត្ថភាពមន្ត្រីថ្នាក់កណ្តាល រាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ

-បន្តរៀបចំសេចក្តីព្រាងអនុក្រឹត្យ ស្តីពីការកំណត់អត្រាភាគទានសម្រាប់ទ្រទ្រង់ ប.ជ.អ

-បន្តពង្រឹងការផ្ទៀងផ្ទាត់ និងតាមដាន ត្រួតពិនិត្យការបើកផ្តល់របបសន្តិសុខសង្គមរបស់អតីតយុទ្ធជននិងគ្រួសារ និងគ្រប់គ្រងថវិកានៅតាមប្រព័ន្ធធនាគារ

-បន្តកែសម្រួលប្រាក់របបសន្តិសុខសង្គមជូនអតីតយុទ្ធជន និងគ្រួសារអតីតយុទ្ធជន មុខឆ្នាំ ២០១៣ ឲ្យមានតុល្យភាពជាមួយអ្នកក្រោយឆ្នាំ២០១៣

-បន្តអនុវត្តគោលការណ៍ស្តីពីការកំណត់អត្តសញ្ញាណកងកម្លាំងប្រដាប់អាវុធចូលនិវត្តន៍ ចូលបាត់បង់សមត្ថភាពការងារ ពិការ និងគ្រួសារយុទ្ធជនពលី មរណៈ ដែលត្រូវទទួលសម្បទានដីសង្គមកិច្ច

-សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ក្នុងការផ្តល់សម្បទានដីសង្គមកិច្ច ជូនអតីតកងកម្លាំងប្រដាប់អាវុធចូលនិវត្តន៍ ចូលបាត់បង់សមត្ថភាពការងារ ពិការ និងគ្រួសារយុទ្ធជនពលី មរណៈ ដែលមិនទាន់បានទទួល

-អភិវឌ្ឍសមាគមអតីតយុទ្ធជនកម្ពុជា សំដៅបន្តជួយដល់អតីតយុទ្ធជនក្នុងការកសាងជីវភាពគ្រួសារ ចូលរួមអភិវឌ្ឍសហគមន៍ ការបន្តសកម្មភាពបេឡាមរណសង្គ្រោះ ការសាងសង់ផ្ទះ ការអភិវឌ្ឍសហគមន៍អតីតយុទ្ធជន។ បង្កលក្ខណៈដល់អតីតយុទ្ធជនឲ្យទទួលបាននូវសេវាសាធារណៈផ្សេងៗដូចជា ការបណ្តុះបណ្តាលវិជ្ជាជីវៈ ការស្តារលទ្ធភាពពលកម្មកាយសម្ព្ធា ការទទួលជំនួយសង្គ្រោះបន្ទាន់ ការចូលរួមសកម្មភាពសិល្ប: កីឡា។ល។

-បន្តនិរន្តរភាពតំបន់អភិវឌ្ឍយោធិនពិការ ដែលជាអំណោយដ៏ថ្លៃថ្លារបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិតនៅបណ្តាភូមិអភិវឌ្ឍន៍យោធិនពិការតាកែនកោះស្លា ស្រុកឈូក ខេត្តកំពត មណ្ឌលអភិវឌ្ឍន៍យោធិនពិការ ៣១៧ ស្រុកគូលែន ខេត្តសៀមរាប និងមណ្ឌលអភិវឌ្ឍន៍យោធិនពិការភ្នំដ៏ត្រ ខេត្តបន្ទាយមានជ័យ និងតំបន់ដទៃមួយចំនួនទៀត។

៧-សិក្សាស្រាវជ្រាវប្រព័ន្ធសន្តិសុខសង្គមទូលំទូលាយ សម្រាប់ប្រជាជនកម្ពុជា

-ជំរុញឲ្យមានសិក្សាស្រាវជ្រាវឯកសារនានា ដើម្បីរៀបចំបង្កើតប្រព័ន្ធសន្តិសុខសង្គមទូលំទូលាយសម្រាប់ប្រជាជនទូទៅ។

៨-អភិវឌ្ឍសមត្ថភាពស្ថាប័ន និងពង្រឹងភាពជាដៃគូ

-បន្តខិតខំកសាងសមត្ថភាពស្ថាប័ន ពង្រឹងស្មារតីទទួលខុសត្រូវមនសិការវិជ្ជាជីវៈរបស់មន្ត្រីសង្គមកិច្ច គ្រប់លំដាប់ថ្នាក់ដើម្បីឆ្លើយតបទៅនឹងភារកិច្ចក្នុងដំណាក់កាលថ្មីនេះ

-បង្កើនការគាំទ្រដំណើរការវិទ្យាស្ថានជាតិសង្គមកិច្ច សំដៅបណ្តុះបណ្តាលធនធានមនុស្សសម្រាប់ស្ថាប័នរដ្ឋ វិស័យឯកជន និងអង្គការមិនមែនរដ្ឋាភិបាលដែលពាក់ព័ន្ធនឹងការផ្តល់សេវាសង្គមកិច្ច បង្កើនការសិក្សាស្រាវជ្រាវ និងពង្រីកកម្មវិធីសិក្សាផ្សេងៗទៀត ទាំងកម្រិតឧត្តមសិក្សា និងកម្រិតវិញ្ញាបនបត្រ រួមមាន

ជំនាញគណនេយ្យ ធនាគារនិងហិរញ្ញវត្ថុ គ្រប់គ្រងទីផ្សារ ភាសាអង់គ្លេស គោលនយោបាយសាធារណៈ គោលនយោបាយសង្គម គ្រប់គ្រងសាធារណៈ និងរដ្ឋបាលសាធារណៈ

-បន្តអនុវត្តនូវកម្មវិធីកំណែទម្រង់លើគ្រប់ផ្នែក ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ដើម្បីបង្កើនប្រសិទ្ធិភាពនៃការផ្តល់សេវាសង្គមកិច្ច។ បន្តអនុវត្តកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ តាមរយៈការផ្ទេរមុខងារ និងធនធានទៅរដ្ឋបាលថ្នាក់ក្រោមជាតិ

-អនុវត្តការធ្វើសមាហរណកម្មក្របខ័ណ្ឌមន្ត្រីរាជការ តាមគោលការណ៍នៃការរៀបចំមុខងារ សាធារណៈថ្មី

-រៀបចំប្រកាសស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់មន្ទីរ ស.អ.យ រាជធានី ខេត្ត និង ការិយាល័យ ស.អ.យ ក្រុង ស្រុក ខណ្ឌ

-បន្តពង្រឹងភាពជាដៃគូជាមួយអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ ដើម្បីពង្រីកនូវស្មារតី សាមគ្គីធម៌នៅក្នុងសង្គម កៀរគរប្រភពធនធាន ថវិកា សម្ភារៈ បច្ចេកទេសសម្រាប់បម្រើឲ្យសំណូមពរនៃ ការងារសង្គមកិច្ច ការជួយដល់ជនក្រីក្រងាយរងគ្រោះតាមរយៈការកសាងយន្តការនានា លើកទឹកចិត្តដល់អង្គ ការ និងដៃគូអភិវឌ្ឍនានា

-បន្តចុះធ្វើអធិការកិច្ចតាមអង្គការក្រោមឱវាទក្រសួង ដើម្បីពង្រឹងការបំពេញមុខងារ តួនាទី ភារកិច្ច ប្រកបដោយប្រសិទ្ធភាព គណនេយ្យភាព និងតម្លាភាព

-បន្តពិនិត្យ តាមដាន និងបកស្រាយបំភ្លឺរាល់ព័ត៌មានទាំងឡាយណាដែលពាក់ព័ន្ធការងារសង្គម កិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

-លើកកម្ពស់ប្រសិទ្ធភាពការងារ តាមរយៈការអនុវត្តផែនការសវនកម្ម និងបន្តពង្រឹងសមត្ថភាព សវនកម្មផ្ទៃក្នុង។

រាជធានីភ្នំពេញ,.ថ្ងៃទី ០៨ ខ្ទែ តុលា ឆ្នាំ២០១៤

ឧបន្ត្រី

ទ ស្ទត

- ជូនភ្នាប់តារាងសូចនាការ និងចំណុចដៅ